00323194

D158/5/3/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | | |
|---|---|---|
| **សំណុំរឿង** | **៖** | ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ ~~២៩~~ ២០) |
| **បញ្ជូនទៅ** | **៖** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃឯកសារ** | **៖** | ថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០០៩ |
| **ភាគីបញ្ជូន** | **៖** | មេធាវីការពារក្តី អៀង សារី |
| **ភាសាដើម** | **៖** | អង់គ្លេស |
| **ចំណាត់ថ្នាក់ឯកសារ ដែលស្នើដោយភាគី** | **៖** | សាធារណៈ |

**ឯកសារបានទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 05 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

---

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និង សំណើសុំចាត់ការសវនាការដោយផ្ទាល់មាត់ឲ្យឆាប់រហ័ស**

---

**<u>បញ្ជូនដោយ</u>៖**

**សហមេធាវី**

អាង ឧត្តម

Michael G. KANAVAS

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Try

**<u>ចែកចាយជូន</u>៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**សហមេធាវីការពារលោក នួន ជា**

**សហមេធាវីការពារលោក ខៀវ សំផន**

**សហមេធាវីការពារលោកស្រី អៀង ធីរិទ្ធ**

**មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី**

**សេចក្តីផ្តើម**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីលោកអៀងសារី") សូមដាក់បណ្តឹងឧទ្ធរណ៍នេះប្រឆាំងនឹងដីកាសម្រេចលើសំណើសុំអោយបំពេញកិច្ចស៊ើបសួរ ដែលចេញដោយសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍")។[1] ជាសារវ័ន្ត ក.ស.ច.ស បានបដិសេធសំណើសុំអោយបំពេញកិច្ចស៊ើបសួរលើកទី ១១ របស់មេធាវីលោក នួន ជា ដោយសំអាងថាសំណើសុំនោះស្ថិតនៅក្រៅយុត្តាធិការដើម្បី "លាតត្រដាងការពិត" របស់ ក.ស.ច.ស ដែលជាអំណាចមួយដែល ក.ស.ច.ស រកឃើញថាមានកម្រិតត្រឹមតែទៅលើឧក្រិដ្ឋកម្មដែលគេចោទប្រកាន់។ ក្នុងការរកឃើញនេះ ក.ស.ច.ស បានភន្ត័ច្រឡំជាសារវ័ន្តអំពីប្រភេទនៃសំណើសុំ ដែលបានស្នើសុំដោយមេធាវីលោក នួន ជា[2] និងបន្ទាប់មកបានត្រឹមតែបដិសេធសំណើសុំមួយដែលការពិតគេមិនបានស្នើប៉ុណ្ណោះ។ វិសាលភាពនៃសំណើសុំ[3] ដូចដែលបានមេធាវីលោកអៀង សារី បានចូលរួមកាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩[4] គឺមានភាពជាក់លាក់ ដោយបានស្នើសុំ៖ (១) លទ្ធផលនៃការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ OIOS ("របាយការណ៍ OIOS")។ (២) រាល់លិខិតឆ្លើយឆ្លងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង។ (៣) ព័ត៌មានទាំងឡាយលើកឡើង អំពីអំពើពុករលួយជាស្ថាប័នដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")[5]។ សំណើសុំបានត្រឹមតែ<u>អញ្ជើញ</u> ក.ស.ច.ស "ធ្វើសំណើអោយមានការស៊ើបអង្កេតផ្នែករដ្ឋបាលមួយទៅលើករណីចោទប្រកាន់អំពីអំពើពុករលួយ ដែលមិនទាន់បានដោះស្រាយនៅក្នុងតុលាការនេះ"។[6] គោលបំណងនៃសំណើសុំនេះ និងតាមលក្ខណៈសមហេតុផលលើការបន្តប្តឹងឧទ្ធរណ៍ គឺដើម្បីអោយគេផ្តល់មកអោយមេធាវីការពារក្តីនូវ

---

[1] រឿងក្តី នួន ជា, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ("ដីកាសម្រេចរបស់ ក.ស.ច.ស")។

[2] រឿងក្តី នួន ជា, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ("សំណើសុំ")។

[3] ដូចដើងទំព័រខាងលើ, កថាខណ្ឌ២២។

[4] រឿងក្តី អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ញត្តិរបស់លោក អៀង សារី សុំចូលរួម និងទទួលយកតាមសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរទី១១ របស់ នួន ជា, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ("ញត្តិសុំចូលរួម")។

[5] ជាសរុបហៅថា "ព័ត៌មានដែលបានស្នើសុំ"។

[6] សំណើសុំ កថាខណ្ឌ ២២។

ព័ត៌មានដែលបានស្នើសុំ ដើម្បីពិនិត្យមើលអំពីផលប៉ះពាល់នៃអំពើពុករលួយ៖ (ក) ការសន្និដ្ឋានលើអង្គហេតុដែលត្រូវបានសំរេច ឬនឹងត្រូវបានសំរេចដោយ ក.ស.ច.ស ដើម្បីវាយតម្លៃលើភស្តុតាងដែល ក.ស.ច.ស បានប្រមូលឬវាយតម្លៃ ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង/ឬ (ខ) ភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចស៊ើបសួររបស់តុលាការដោយខ្លួនឯង។ ដូច្នេះ ធាតុទាំងបីនៃសំណើសុំនេះគឺត្រូវបានចង្អុលបង្ហាញយ៉ាងជាក់លាក់ ជាប់ទាក់ទិនយ៉ាងប្រត្យក្សទៅនឹងសិទ្ធិទទួលបានសវនាការយុត្តិធម៌ដែលបាត់បង់គុណភាព និងដោយច្បាស់លាស់មែនទែនវាស្ថិតនៅក្នុងអំណាចតាមផ្លូវច្បាប់ និងអំណាចមានពីកំណើតរបស់ ក.ស.ច.ស ដើម្បីបំពេញតាមសំណើនេះ។

## I ប្រវត្តិនៃអង្គហេតុ

១. ដូចដែលបានលើកឡើងយ៉ាងទូលំទូលាយក្នុងសំណើសុំ ការចោទប្រកាន់ដែលមិនទាន់បានដោះស្រាយអំពីការប្រព្រឹត្តអំពើពុកលួយនៅ អ.វ.ត.ក បានចោមរោមចោទជាសំណួរដល់អង្គជំនុំជម្រះនេះ អស់រយៈពេលជាងពីរឆ្នាំមកហើយ។[7] សម្រាប់ជាផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចតុលាការ មេធាវីលោក អៀង សារី បានដាក់បញ្ចូលប្រវត្តិនៃអង្គហេតុទាំងនោះជាសេចក្តីយោង។

២. ចាប់តាំងពីពេលដាក់សំណើសុំ របាយការណ៍ជាបន្តបន្ទាប់ដែលបានមកពីស្ថាប័នព័ត៌មានអន្តរជាតិល្បីៗចំនួនពីរគឺ CNN និងទស្សនាវដ្តី The Economist ដែលបានផ្សព្វផ្សាយពាក់ព័ន្ធអំពីការចោទប្រកាន់អំពើពុករលួយដែលស្ថិតនៅជាបេះដូងនៃ អ.វ.ត.ក ។

ក. នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ CNN បានបង្ហាញនូវព័ត៌មានមួយដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើពុករលួយជាប្រព័ន្ធនៅក្នុង អ.វ.ត.ក ។ ជាពិសេសការសម្ភាសន៍ជាមួយនឹងអតីតបុគ្គលិកមួយចំនួនមកពីភាគីជាតិរបស់ អ.វ.ត.ក បានបញ្ជាក់យ៉ាងពិស្តារអំពីនីតិវិធីនៃរបៀបនៃការប្រមូលលុយពីបុគ្គលិក និងអ្នកដែលត្រូវគេប្រគល់លុយឱ្យ។[8] ភ្លាមៗនៅ

---

[7] ដូចយោងខាងលើ កថាខណ្ឌ ៥-១១។

[8] *សូមមើល* ឧបសម្ព័ន្ធ ក. ប្រតិចារិតនៃសេចក្តីរាយការណ៍ព័ត៌មានទូរទស្សន៍ CNN មានចំណងជើងថា "តុលាការឧក្រិដ្ឋកម្មសង្គ្រាមស្ថិតក្នុងការស៊ើបអង្កេតពីបទពុករលួយ", ចាក់ផ្សាយតាមរលកធាតុអាកាស CNN នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។ *សូមមើលផងដែរ* ប្រតិចារិតនៃភាពយន្តឯកសាររបស់ទូរទស្សន៍ CNN មានចំណងជើងថា "រឿងរ៉ាវដែលកប់បាត់របស់ពិភពលោក៖ វាលពិឃាត៖ ផ្លូវវែងឆ្ងាយឆ្ពោះទៅរកយុត្តិធម៌ (World Untold Stories: Killing fields: Long Way to

ក្នុងថ្ងៃដដែលនោះ ក្នុងការឆ្លើយតបទៅនឹងអំណោយរបស់រដ្ឋាភិបាលជប៉ុនចំនួន ២០០.០០០ ដុល្លា ដែលបានផ្តល់ឱ្យសម្រាប់បើកប្រាក់ខែឱ្យបុគ្គលិកជាតិនៅ អ.វ.ត.ក[9] សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមាក់ងាយដល់តុលាការនៅក្នុងសុន្ទរកថាមួយដែលគាត់បាននិយាយថា គាត់ចង់ឃើញតុលាការនេះអស់លុយ ដោយនិយាយថា "ខ្ញុំបន់ឱ្យតុលាការអស់លុយក្នុងពេលឆាប់ៗ"។[10]

ខ. នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ និងការពិតគឺមួយថ្ងៃមុនការចេញដីកាសម្រេចរបស់ ក.ស.ច.ស ទស្សនាវដ្តី Economist បានផ្សាយអត្ថបទមួយដែលរៀបរាប់លំអិតបន្ថែមទៀតលើករណីចោទប្រកាន់អំពើពុករលួយទាំងនេះ[11]។ អត្ថបទនេះចោទប្រកាន់ថា "មានបុគ្គលិកតុលាការនេះចំនួន ៣ នាក់ ដែលបាននិយាយក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះចោទប្រកាន់លោក ស៊ាន វិសុទ្ធ ដែលជាប្រធានការិយាល័យរដ្ឋបាលនៃតុលាការនេះ ថាបានប្រមូលលុយកាក់ពីបុគ្គលិកកម្ពុជាទាំងឡាយនៅក្នុងការិយាល័យរបស់គាត់ រួមមានទាំងបុគ្គលិកតុលាការ និង<u>បុគ្គលិកជំនួការច្បាប់ជាតិនៅក្នុងនានានៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា</u>។ បុគ្គលិកទាំងនោះត្រូវបានគេប្រាប់ថាប្រាក់កាសនេះមួយចំនួនគឺក្នុងគោលបំណងសំរាប់អោយ សុខ អាន ដែលជាឧបនាយករដ្ឋមន្ត្រី"[12]។ ការចោទប្រកាន់នេះគឺកាន់តែធ្ងន់ធ្ងរឡើងជាងការចោទប្រកាន់ដែលលេចចេញនាអំឡុងពេល ២ ឆ្នាំមុន ដែលវាទាក់ទងនឹងអំពើពុករលួយមិនមែនតែក្នុងការិយាល័យរដ្ឋបាលប៉ុណ្ណោះទេ ប៉ុន្តែអំពើពុករលួយដែលមាននៅក្នុង ក.ស.ច.ស និងការិយាល័យសហព្រះរាជអាជ្ញា។ គួរអោយរំលឹកឡើងវិញផងដែរថា អត្ថបទនោះក៏បាន

---

Justice)" ដែលបានចាក់ផ្សាយតាមរលកធាតុអាកាស CNN នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ២០០៩ ដែលផ្សាយឡើងវិញ និងមានការវិវឌ្ឍន៍បន្ថែមនៃរបាយការណ៍នេះ។

[9] *សូមមើល* សេចក្តីប្រកាសព័ត៌មានពីស្ថានទូតជប៉ុន មានចំណងជើងថា "ជំនួយជប៉ុនសម្រាប់គម្រោងពង្រឹងដំណើរការតុលាការក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", ចេញផ្សាយថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩។

[10] Andrew Buncombe, *The Independent*, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩, "មេគុកខ្មែរក្រហមសុំខមាទោស"។

[11] *សូមមើល* ទស្សនាវដ្តី Economist ចេញផ្សាយថ្ងៃទី ២ ខែមេសា ឆ្នាំ២០០៩ ក្រោមចំណងជើងថា៖ តុលាការនេះបើកការជំនុំជម្រះ មានការចោទប្រកាន់ពីអំពើពុករលួយគំរាមកំហែងដល់ភាពជឿរជាក់មកលើតុលាការខ្មែរក្រហម ("អត្ថបទទស្សនាវដ្តី Economist")។

[12] គួសបញ្ជាក់បន្ថែម។

បញ្ជាក់ផងដែរជាមួយប្រធានការិយាល័យរដ្ឋបាលលោក ស៊ាន វិសុទ្ធ ដែលថាមាន "របាយការណ៍ត្រួតពិនិត្យមួយអំពើពុករលួយរបស់អង្គការសហប្រជាជាតិ បានលើកឡើងអំពីឈ្មោះរបស់គាត់ និងបានស្នើសុំឱ្យដករូបគាត់ចេញ។"

៣. នៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩ នៅពេលដែលមេធាវីលោក អៀង សារី បានព្យាយាមលើកឡើងនូវបញ្ហាអំពើពុករលួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន[13] ការលើកឡើងនេះត្រូវបានទប់ស្កាត់។[14] ប៉ុន្តែក្នុងពេលឆ្លើយតបទៅនឹងការព្យាយាមលើកឡើងរបស់មេធាវីលោក អៀង សារី សហព្រះរាជអាជ្ញាបានលើកឡើងថា "វាគឺជាការយល់ដឹងជាសាធារណៈដែលពាក្យសុំមួយទាក់ទងនឹងបញ្ហាអំពើពុករលួយត្រូវលើកឡើងចំពោះមុខ [សហចៅក្រមស៊ើបអង្កេត]។"[15]

៤. ក្នុងសប្តាហ៍បន្ទាប់គឺថ្ងៃទី ០៦ ទី ០៧ ទី ០៨ ខែមេសា ឆ្នាំ២០០៩ ឯកឧត្តម Peter Taksoe-Jensen បានមកដល់ទីក្រុងភ្នំពេញ ជួបជាមួយឯកឧត្តម សុខ អាន ដើម្បីពិភាក្សាអំពីការចោទប្រកាន់អំពើពុករលួយដែលចេះតែបន្តមាននៅ អ.វ.ត.ក និងដើម្បីបង្កើតយន្តការមួយសម្រាប់រាយការណ៍អំពីការប្រព្រឹត្តអំពើពុករលួយនាពេលអនាគតទៅដល់ភាគីទាំងពីគឺភាគីជាតិ និងអង្គការសហប្រជាជាតិនៅក្នុង អ.វ.ត.ក ។ តាមរយៈការព្រមទទួលយក និងថ្វីបើតាមឆន្ទះរបស់លោក Peter Taksoe-Jensen "ក្នុងការទុកបញ្ហានៃអំពើពុករលួយនេះមួយអន្លើសិន" (*ហេតុដូច្នេះ ការធ្វើពុតថាអ្វីៗទាំងអស់គឺល្អប្រសើរ ជាឥរិយាបថមួយដែលត្រូវតែបានគេពិចារណាដើម្បីឆ្លុះបញ្ចាំងពីគោលនយោបាយផ្លូវការរបស់អង្គការសហប្រជាជាតិ ចំពោះការចោទប្រកាន់ពីអំពើពុករលួយ*) ក៏កិច្ចប្រជុំនោះបានទទួលបរាជ័យ គឺគ្មានបានបង្កើត ឬយល់ស្របគ្នាលើយន្តការដ៏គួរឱ្យជឿទុកចិត្តមួយ ដើម្បីដោះស្រាយបញ្ហានៃការចោទប្រកាន់អំពើពុករលួយឡើយ។[16]

---

[13] *រឿងក្តី* អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៧), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នរបស់ ក.ស.ច.ស, ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨។

[14] រឿងក្តីរបស់ អៀង សារី, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៧), ប្រតិចារឹកនៃសវនាការថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩, ទំព័រ ៣៣។

[15] ដូចយោងខាងលើ ទំព័រ ២៦ ។

[16] *សូមមើល* ឧបសម្ព័ន្ធ គ។ សេចក្តីថ្លែងការរបស់ Peter Taksoe-Jensen, ភ្នំពេញ, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩។

ទោះបីជាមានការបរាជ័យដូចនេះក៏ដោយ ក៏ក្រោយពេលកិច្ចប្រជុំមានរបាយការណ៍លើកឡើងថា ប្រទេសផ្តល់ជំនួយមួយចំនួនសម្រាប់ អ.វ.ត.ក ដូចជាប្រទេសអូស្ត្រាលី បានដាក់សម្ពាធដល់លោក Peter Taksoe-Jensen ឲ្យទទួលយកយន្តការប្រឆាំងអំពើពុករលួយមិនគ្រប់ជ្រុងជ្រោយមួយដែលស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង "ស្នើឲ្យបញ្ចេញថវិការបស់ប្រទេសអូស្ត្រាលីសម្រាប់តុលាការខ្មែរក្រហមដែលបានត្រូវបង្កកទុកកាលពីឆ្នាំទៅ ដោយសារតែការចោទប្រកាន់អំពីការផ្តល់លុយជាថ្នូរនឹងការងារ"[17]។ ប៉ុន្តែ វាទំនងជាថា រហូតមកដល់សព្វថ្ងៃនេះ អង្គការសហប្រជាជាតិបានជំទាស់នឹងការបញ្ចេញថវិកានេះ "លុះត្រាតែបញ្ហានៃអំពើពុករលួយត្រូវបានដោះស្រាយអោយបានគ្រប់គ្រាន់"[18]។

## II. ការកត់សម្គាល់ជាបឋម

### ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៥. សំណើសុំត្រូវបានដាក់ "អនុលោមតាមវិធាន ២១(១), ៥៥(១០) និង ៥៨(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន")[19]។ យោងតាមវិធាន ៧៤(៣)(ខ) ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍លើដីការបស់ ក.ស.ច.ស "ដែលបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដែលបានអនុញ្ញាតដោយវិធានផ្ទៃក្នុងទាំងនេះ"។ ដីការបស់ ក.ស.ច.ស បានបដិសេធយ៉ាងច្បាស់លាស់លើសំណើសុំអោយបំពេញកិច្ចស៊ើបសួរ ហេតុដូច្នេះសំណើសុំនេះអាចទទួលយកបានស្របតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។

៦. បណ្តឹងឧទ្ធរណ៍នៅតែអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ខ) ទោះបីជាសហចៅក្រមស៊ើបអង្កេតបានប្រកាសថា "ខ្លួនមានកង្វះខាតផ្នែកយុត្តាធិការក្នុងការបំពេញកិច្ច

---

[17] រដ្ឋាភិបាលនិយាយថា ខ្លួនត្រូវបានគាំទ្រដោយម្ចាស់ជំនួយនៅក្នុងកិច្ចពិភាក្សាតុលាការ, ដោយ Douglas Gillison និង Isabelle Roughol, កាសែត Cambodia Daily, ចេញថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៩។

[18] អត្ថបទផ្សាយរបស់ វិទ្យុសម្លេងអាមេរិច VoA ដោយលោក សុខ ខេមរា នាថ្ងៃទី ២៣ មេសា ២០០៩ ក្រោមចំណងជើងថា "អង្គការសហប្រជាជាតិ៖ ការបរាជ័យរបស់តុលាការទម្លាក់បន្ទុកមកលើម្ចាស់ជំនួយ" ("អត្ថបទរបស់ខេមរា")។

[19] សំណើសុំ, កថាខណ្ឌទី១។

ស៊ើបសួរដូចដែលបានស្នើសុំ"[20] ជាជាងសម្រេចសេចក្តីទៅលើខ្លឹមសារនៃសំណើសុំ[21]។ ចំពោះការផ្តល់សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ដែលបានបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនោះ វិធាន ៧៤(៣)(ខ) មិនបានបែងចែកថា តើសំណើសុំនេះត្រូវបានបដិសេធដោយសារតែខ្លឹមសារ ឬបដិសេធដោយសារតែកង្វះយុត្តាធិការ។ ការពិតដែលសំណើសុំនោះត្រូវបានបដិសេធ គឺជាកត្តាដែលបានលេចចេញតែមួយគត់ដែលត្រូវយកទៅធ្វើការពិចារណា ហើយដែលបានផ្តល់សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នោះ។

៧. សំណើសុំត្រូវបានដាក់ដោយមេធាវីលោក នួន ជា កាលពីថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០០៩។ មេធាវីលោក អៀង សារី[22] និងមេធាវីលោក ខៀវ សំផន[23] បានដាក់ពាក្យសុំដើម្បីចូលរួមក្នុងសំណើសុំនោះជាបន្តបន្ទាប់ ដោយមានការដាក់ ពាក្យសុំគាំទ្រពីមេធាវីលោកស្រី អៀង ធីរិទ្ធ ផងដែរ[24]។ ដោយបានចូលរួមក្នុងសំណើសុំនោះដែរ មេធាវីលោកអៀង សារី បានជូនដំណឹងដល់លោក អៀង សារី ថាខ្លួន"សូមទទួលយកដោយឥតលក្ខខណ្ឌនូវអំណះអំណាងផ្លូវច្បាប់ និងអង្គហេតុនានាដែលរៀបចំដោយមេធាវីលោក នួន ជា"[25]។ ដោយបានចូលរួមក្នុងសំណើសុំដូច្នេះ មេធាវីលោក អៀង សារី មានសិទ្ធិពេញលេញដើម្បីប្តឹងឧទ្ធរណ៍អនុលោមតាមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង។ ដីកាសម្រេចរបស់ ក.ស.ច.ស ដោយសំដៅមកគ្រប់ក្រុមមេធាវីការពារក្តីដែលបានចូលរួម ឬគាំទ្រសំណើសុំនេះ បានយល់ស្របការអង្គហេតុនេះ ។

---

[20] ដីកាសម្រេចរបស់ ក.ស.ច.ស ក្នុងផ្នែកសម្រេចសេចក្តី។

[21] *សូមមើលផងដែរ* ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌទី១០ ថាតើ ក.ស.ច.ស អះអាងថា "ដោយមិនគិតអំពីភាពសមហេតុផលនៃការចោទប្រកាន់ ដែលបានលើកឡើងនៅក្នុងសំណើសុំ បញ្ហាគឺថា ការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំបែបនោះ វាគឺជាការប្រើប្រាស់អំណាចក្នុងផ្លូវខុស ព្រោះអង្គហេតុទាំងនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតដោយអនុលោមតាមច្បាប់ អ.វ.ត.ក"។

[22] *សូមមើល* ញត្តិសុំចូលរួម, ទំព័រទី១។

[23] រឿងក្តី ខៀវ សំផន សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីថ្លែងការណ៍របស់ក្រុមមេធាវីការពារក្តីដើម្បីឲ្យអនុម័តយកសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១១ របស់ នួន ជា ទាក់ទងនឹងការចោទប្រកាន់អំពើបទពុករលួយនៅ អ.វ.ត.ក, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩។

[24] រឿងក្តី អៀង ធីរិទ្ធ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ញត្តិគាំទ្រសំណើសុំធ្វើកិច្ចស៊ើបសួរលើកទី១១ របស់លោក នួន ជា ដើម្បីលាតត្រដាងពីរបាយការណ៍ OIOS និងឯកសារពាក់ព័ន្ធ, ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។

[25] ញត្តិសុំចូលរួម, ទំព័រទី១។

៨. សិទ្ធិប្តឹងឧទ្ធរណ៍របស់លោក អៀង សារី គឺឯករាជ្យពីបណ្តឹងឧទ្ធរណ៍នានាដែលបានដាក់ប្តឹងដោយជនត្រូវចោទដទៃទៀត ដែលមានសិទ្ធិប្តឹងផងដែរ[26]។

## ខ. សំណើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់

៩. អនុលោមតាមវិធាន ៧៧ មេធាវីលោក អៀង សារី ស្នើសុំដោយក្តីគោរពឲ្យមានសវនាការដេញដោលផ្ទាល់មាត់ចំពោះពាក្យបណ្តឹងឧទ្ធរណ៍នេះ។ អនុលោមតាមវិធាន ៧៧(៣) "ការសន្ទតជាមុនចំពោះរាល់បណ្តឹងឧទ្ធរណ៍ទាំងអស់មុនអង្គសេចក្តី គឺនឹងធ្វើតាមរយៈសវនាការដេញដោលផ្ទាល់មាត់"[27] និង អង្គបុរេជំនុំជម្រះបានផ្តល់ឲ្យម្តងហើយម្តងទៀត តាមសំណើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់ ចំពោះបណ្តឹងឧទ្ធរណ៍ដែលមិនមានការឯកភាពគ្នារវាងភាគីនានា[28]។ លក្ខខ័ណ្ឌពីរយ៉ាងដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើយុត្តិកម្មលើសវនាការដេញដោលផ្ទាល់មាត់គឺ៖ (១) សារៈសំខាន់នៃបញ្ហា និង (២) ការពិតដែលថាភាគីមួយក្នុងចំណោមភាគីនានាបានស្នើសុំឲ្យមានសវនាការដេញដោលផ្ទាល់មាត់"[29]។ ចំពោះបណ្តឹងឧទ្ធរណ៍នាពេលបច្ចុប្បន្ននេះ

---

[26] ទោះជាយ៉ាងណាមិនគួរឲ្យភ្ញាក់ផ្អើលទេ មេធាវីលោក នួន ជា មេធាវីលោក ខៀវ សំផន និងមេធាវីលោកស្រី អៀង ធីរិទ្ធ ក៏បានដាក់ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់ ក.ស.ច.ស ផងដែរ។ *សូមមើល រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៩), សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍។ *រឿងក្តី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៩), សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៩។ *រឿងក្តី អៀង ធីរិទ្ធ* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៩), សេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍, ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៩។

[27] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៨), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និង សំណើសុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និង សវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ, ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ("បណ្តឹងឧទ្ធរណ៍ការសម្ងាត់")។

[28] *រឿងក្តី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១១), សេចក្តីសម្រេចលើពាក្យសុំឲ្យមានសវនាការជាសាធារណៈ របស់លោក ខៀវ សំផន, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៧), សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩, ("សេចក្តីសម្រេចសារណាជាលាយលក្ខណ៍អក្សរ")។

[29] បណ្តឹងឧទ្ធរណ៍ការសម្ងាត់, យោងសេចក្តីសម្រេចសារណាជាលាយលក្ខណ៍អក្សរ, កថាខណ្ឌទី៦។

មេធាវីលោក អៀង សារី កំពុងស្នើសុំយ៉ាងដាក់លាក់អោយមានសវនាការដេញដោលផ្ទាល់មាត់។ អាស្រ័យហេតុនេះ សំណើសុំនេះគួរតែត្រូវផ្តល់ឲ្យ។

១០. ដោយសារតែទាក់ទឹងនឹងខ្លឹមសារ បញ្ហានានាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍តម្រូវឲ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ។ បណ្តឹងឧទ្ធរណ៍គួរតែជាប្រធានបទនៃការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ដោយសារតែ៖

ក. បណ្តឹងឧទ្ធរណ៍លើកឡើងនូវបញ្ហាស្មុគស្មាញ ដែលមិនធ្លាប់បានលើកឡើងកាលពីមុននៅចំពោះមុខអង្គបុរេជំនុំជម្រះ ខណៈដែលអង្គបុរេជំនុំជម្រះបានបដិសេធក្នុងការអនុញ្ញាតឲ្យមានការធ្វើសេចក្តីសន្និដ្ឋានលើបញ្ហានេះដោយសហមេធាវីការពារក្តីជនត្រូវចោទ អៀង សារី ក៏ដូចជាសហមេធាវីការពារក្តីជនត្រូវចោទ ខៀវ សំផន នៅក្នុងសវនាការដេញដោលផ្ទាល់មាត់កាលពីពេលថ្មីៗនេះ[30]។

ខ. បណ្តឹងឧទ្ធរណ៍បានសម្តែងចេញទាំងស្រុងនូវវិបាកបថរបស់ ក.ស.ច.ស ឆ្ពោះទៅរកតម្លាភាព និង ការទទួលខុសត្រូវលើអំពើរបស់ខ្លួន ព្រមទាំងសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីប្រកបដោយភាពយុត្តិធម៌ដែលនឹងមានជាប់ជាមួយនឹងការស៊ើបអង្កេត លើកលែងតែត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះប៉ុណ្ណោះ។

គ. បណ្តឹងឧទ្ធរណ៍បានជះឥទ្ធិពលយ៉ាងច្បាស់លាស់ និងគ្មានមន្ទិលសង្ស័យលើកេរ្តិ៍ដំណែលរបស់ អ.វ.ត.ក ក្នុងការផ្តល់ជាឧទាហរណ៍នូវដំណើរការនីតិវិធីតុលាការប្រកបដោយយុត្តិធម៌និងតម្លាភាពដែលត្រូវបានសន្មតទុកជាមុន[31]។

១១. ដោយសារក្រុមមេធាវីការពារក្តីចំនួន ៤ក្រុម នឹងត្រូវបានធ្វើជាតំណាងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ ដូច្នេះហើយនឹងដាក់សារណាបណ្តឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នានោះ ក្រុមនីមួយៗត្រូវតែទទួល

---

[30] *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៧) ប្រតិចារឹក នៃសវនាការ, ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩, ទំព័រ ៣៣។ *រឿងក្តី ខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ១៥), ប្រតិចារឹក នៃសវនាការ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ទំព័រ ៤៦។

[31] តាមពិតក្នុងកំឡុងពេលចរចារទាក់ទងនឹងការបង្កើត អ.វ.ត.ក អ្នកចរចារ អ.ស.ប មានកង្វល់ថា សេចក្តីរាយការណ៍ជាច្រើននៃអំពើពុករលួយ និងកង្វះឯករាជ្យភាព និងសមត្ថភាពក្នុងប្រព័ន្ធតុលាការកម្ពុជាក្នុងស្រុក អាចរាំងស្ទះតុលាការក្នុងការផ្តល់យុត្តិធម៌ និងបំពេញតាមបទដ្ឋានអន្តរជាតិ។ *សូមមើល* ការកាត់ទោស ឌុច នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, របាយការណ៍របស់ Open Society Justice Initiative, ចុះខែមីនា ឆ្នាំ២០០៩, ទំព័រទី៥។

បាននូវការអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីបង្ហាញទឡ្ហីករណ៍ដោយផ្ទាល់មាត់នៅក្នុងពេលសវនាការដេញដោលផ្ទាល់មាត់។ ក្រុមមេធាវីការពារក្តីនីមួយៗត្រូវតែទទួលបាននូវការអនុញ្ញាតនូវរយៈពេលដូចគ្នា ដើម្បីបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់ទៅលើបណ្តឹងឧទ្ធរណ៍ (រយៈពេលប្រហែលជា ១ម៉ោងកន្លះ សម្រាប់ក្រុមនីមួយៗ) ដោយសារករណីនេះនឹងត្រូវបានអនុញ្ញាតឲ្យប្រសិនបើភាគីនោះប្តឹងឧទ្ធរណ៍តែម្នាក់ឯងនោះ។ ជនត្រូវចោទម្នាក់ៗដែលត្រូវបាននាំយកមកចំពោះមុខ អ.វ.ត.ក មានសិទ្ធិទទួលនូវការកាត់សេចក្តីប្រកបដោយយុត្តិធម៌រៀងៗខ្លួន រីឯអង្គជំនុំជម្រះ ដែលជនត្រូវចោទទាំងនោះត្រូវបង្ហាញខ្លួនចំពោះមុខនោះ មិនអាចកាត់សេចក្តីលើជនទាំងនេះជារួមបានទេ ទោះបីជាជនទាំងនេះអាចចែករំលែកនូវផលប្រយោជន៍ដូចគ្នាក៏ដោយ។

១២. សវនាការដេញដោលផ្ទាល់មាត់ ត្រូវបានស្នើអោយធ្វើឡើងនៅវេលាដែលអង្គបុរេជំនុំជម្រះអាចធ្វើបានឆាប់បំផុតតាមការគួរ នោះគឺនៅពេលដែលអង្គបុរេជំនុំជម្រះនឹងជួបប្រជុំគ្នានៅសប្តាហ៍នៃថ្ងៃទី១ ដល់ ទី៥ នៃខែមិថុនា ឆ្នាំ២០០៩[32]។ ការរកឃើញនូវអំពើពុករលួយដែលបានរីករាលដាល និងមានលក្ខណៈជាប្រព័ន្ធនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ[33] អាចមានផលប៉ះពាល់ដល់ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ក៏ដូចជាការផ្តល់ជំនួយជាបន្តដល់ខាងភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ របស់អង្គការកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) និងជាលទ្ធផលគឺការបន្តកិច្ចដំណើរការនីតិវិធីតុលាការនោះ ។ ផលប៉ះពាល់នេះគឺពិតប្រាកដ និងតម្រូវអោយមានការចាត់វិធានការមួយដែលមានតម្លាភាព ដោយមានមនសិការ និងអោយបានឆាប់រហ័ស។

## III. សេចក្តីសង្ខេបទឡ្ហីករណ៍

[32] យោងតាមអង្គបុរេជំនុំជម្រះ ខ្លួននឹងបើកសវនាការផ្ទាល់មាត់បន្ទាប់ នៅសប្តាហ៍ទី១-៥ ខែមិថុនា ឆ្នាំ២០០៩។ *សូមមើល រឿងក្តី អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, អនុស្សរណៈអន្តរការិយាល័យ, កិច្ចប្រជុំអង្គបុរេជំនុំជម្រះលើកដំបូងក្នុងឆមាសទីមួយនៃឆ្នាំ២០០៩, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨។

[33] *សូមមើល* មាត្រាទី២៨ នៃកិច្ចព្រមព្រៀងដែលអនុញ្ញាតឲ្យ អ.ស.ប "ផ្អាកជំនួយឧបត្ថមជាហិរញ្ញវត្ថុ ឬជាអ្វីផ្សេងទៀតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងគ្នានេះ" ប្រសិនបើ "រាជរដ្ឋាភិបាលកម្ពុជាផ្លាស់ប្តូររចនាសម្ព័ន ឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ឬក៏ធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះដំណើរការតាមរបៀបណាមួយដែលមិនស្របជាខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ" ។

១៣. មេធាវីលោកអៀង សារី សុំដាក់ជូននូវអំណះអំណាងដូចខាងក្រោម ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍របស់ខ្លួន៖

ក. ក.ស.ច.ស បានប្រកាន់យកនូវវិធីសាស្ត្រតឹងរឹងជ្រុលមួយ ក្នុងកំណត់ដែនយុត្តាធិការតាមផ្លូវច្បាប់របស់ខ្លួនដើម្បីបដិសេធសំណើសុំនេះ។ ព័ត៌មានដែលបានស្នើសុំដល់ ក.ស.ច.ស តាមរយៈសំណើសុំនេះ ស្ថិតនៅក្នុងរង្វង់ដែនសមត្ថកិច្ចតាមផ្លូវច្បាប់របស់ ក.ស.ច.ស តាមកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក[34] តាមច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[35] និងវិធានផ្ទៃក្នុង[36]។ ហេតុដូច្នេះ ព័ត៌មានដែលបានស្នើសុំគឺមិន "ថ្មីទាំងស្រុងទៅនឹងអង្គហេតុដែលគ្របដណ្តប់ដោយកិច្ចស៊ើបសួររបស់តុលាការនាពេលបច្ចុប្បន្ននេះឡើយ[37]" ប៉ុន្តែនេះវាបង្កើតបានជាផ្នែកមួយជាប់មកជាមួយ និងមិនអាចផ្តាច់ចេញបានពីការស៊ើបសួរ។

ខ. ថ្វីបើមានការចោទប្រកាន់ថាមានការដាក់កម្រិតដោយច្បាប់ចំពោះ ក.ស.ច.ស ក្នុងការផ្តល់ឲ្យនូវព័ត៌មានដែលបានស្នើសុំ ក.ស.ច.ស មានអំណាច និងភារកិច្ចពីកំណើតក្នុងការតាក់តែងបទបញ្ញត្តិសម្រាប់កិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ នៅក្នុងក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលតម្រូវឲ្យផ្តល់ឲ្យនូវព័ត៌មានដែលបានស្នើសុំដល់ក្រុមមេធាវីការពារក្តី ។

គ. សំណើសុំ គឺមិនមែនធ្វើឡើងដោយផ្អែកលើ "ការប្រមើលមើលអំពីផលវិបាកជាអវិជ្ជមាន ក្នុងគ្រប់ទម្រង់ទាំងអស់នៃអំពើពុករលួយ ប្រសិនបើកើតមាននៅក្នុងដំណើរការនីតិវិធីតុលាការ"[38] ប៉ុន្តែ ដោយផ្អែកលើការបកស្រាយសមហេតុផលនៃភស្តុតាងដែលជនត្រូវចោទ/ក្រុមមេធាវីការពារក្តីទទួលបាន។ ព័ត៌មានជាច្រើនទៀតអំពីវិសាលភាពនៃអំពើពុករលួយនៅក្នុង អ.វ.ត.ក ដែលជាលទ្ធផលនាំឲ្យមានដីការសម្រេចបស់ ក.ស.ច.ស បញ្ជាក់បន្ថែមអំពីការចោទប្រកាន់ទាំងនេះ។

---

[34] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹតឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង")។

[35] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹតឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤, នស/រកម/១០០៤/០០៦ ("ច្បាប់ស្តីពីការបង្កើត")។

[36] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៣), ដែលបានធ្វើវិសោធនកម្មថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៩ ("វិធាន")។

[37] ដីកាសម្រេចរបស់ ក.ស.ច.ស, កថាខណ្ឌទី១០។

[38] ដីកាសម្រេចរបស់ ក.ស.ច.ស, កថាខណ្ឌទី១២។

ឃ. ធាតុចម្បងនៃព័ត៌មានដែលបានស្នើសុំ ដែលហៅថា របាយការណ៍ OIOS មិនមែនជាកម្មសិទ្ធិរបស់រដ្ឋាភិបាលកម្ពុជាទេ តែជារបស់អង្គការសហប្រជាជាតិ ដែលផ្តួចផ្តើមធ្វើឡើងតាមរយៈការស៊ើបអង្កេតរបស់ OIOS ។ ដូច្នេះ របាយការណ៍ OIOS ត្រូវតែកម្មវត្ថុនៃការបំពេញកិច្ចស៊ើបសួរ ហើយ ក.ស.ច.ស មិនអាចលាក់ខ្លួនពីក្រោយខ្នងការបដិសេធរបស់រដ្ឋាភិបាលកម្ពុជា នូវសំណើសុំឯកសារនេះដែលធ្វើឡើងដោយ ជនត្រូវចោទ/ក្រុមមេធាវីការពារក្តីឡើយ។

ង. ជម្រើសផ្សេងនឹងករណីនេះ បើសិន របាយការណ៍ OIOS អាចគ្រាន់តែទទួលបានតាមរយៈការបំពេញកិច្ចស៊ើបសួរមួយដោយ ក.ស.ច.ស ដោយធ្វើដោយផ្ទាល់ទៅកាន់រដ្ឋាភិបាលកម្ពុជា*តាមរយៈ*សំណើសុំជំនួយ ស្របតាមមាត្រា ២៥នៃកិច្ចព្រមព្រៀង ឬ ក្នុងវិធានដែល ពាក់ព័ន្ធទៅនឹងសំណើសុំឱ្យលាតត្រដាងនូវព័ត៌មាន ដែលស្ថិតនៅក្រោមយុត្តិសាស្ត្រអន្តរជាតិ ដែលឆ្លើយតបទៅនឹងគ្រប់លក្ខណៈវិនិច្ឆ័យសំខាន់ៗទាំងអស់។

## IV. អំពីអង្គច្បាប់

### ក. យុត្តាធិការលើការស៊ើបអង្កេតរបស់តុលាការ

១៤. តាមមាត្រា ៥(១) នៃកិច្ចព្រមព្រៀង ក.ស.ច.ស ត្រូវទទួលខុសត្រូវតាមច្បាប់ និងផ្តាច់មុខតែម្នាក់ឯងក្នុងការបំពេញកិច្ចស៊ើបសួរមុនអង្គសេចក្តី។ ខណៈដែលក្រុមមេធាវីការពារក្តីអាចស្នើសុំឱ្យ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរជាក់លាក់នោះ ក្រុមមេធាវីទាំងនោះត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតផ្ទាល់ខ្លួន ហើយត្រូវតែបញ្ជូនរាល់សំណើសុំអោយបំពេញកិច្ចស៊ើបសួរទាំងអស់ទៅកាន់ ក.ស.ច.ស[39]។ គោលបំណងនៃយុត្តាធិការផ្តាច់មុខតែម្នាក់ឯងនេះគឺច្បាស់លាស់ គឺដើម្បីការពារសុចរិតភាព និងឯករាជ្យភាពនៃការស៊ើបសួរពីការជ្រៀតជ្រែកពីបណ្តាភាគីនានា ពោលគឺ សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី ។

---

[39] ក.ស.ច.ស បានបញ្ជាក់ពីមុនអំពីតួនាទីរបស់ភាគីទាក់ទងនឹងការស៊ើបអង្កេតរបស់ អ.វ.ត.ក៖ “ នៅមុខអង្គជំនុំជម្រះនេះ អំណាចនៃការធ្វើការស៊ើបអង្កេតុលាការ ត្រូវចាត់តាំងឱ្យតែ សហចៅក្រមស៊ើបអង្កេតឯករាជ្យពីរនាក់តែប៉ុណ្ណោះ ហើយមិនត្រូវចាត់តាំងឱ្យភាគីណាផ្សេងឡើយ។ មិនមានការអនុញ្ញាតណាមួយ ដែលផ្តល់អំណាចឱ្យភាគីទាំងឡាយ ដើម្បីសម្រេចកិច្ចស៊ើបអង្កេតជំនួសឱ្យសហចៅក្រមស៊ើបអង្កេតឡើយ ដូចដែលអាចជារណីនៅក្នុងប្រព័ន្ធនីតិវិធីផ្សេងៗ។ [...] សមត្ថភាពរបស់ភាគីទាំងឡាយ ដើម្បីអន្តរាគមន៍ត្រូវបានកំណត់ទៅតាមការស៊ើបអង្កេតដំបូង ដូចដែលចាំបាច់ខ្លាំងសម្រាប់ការនុវត្តន៍ដ៏មានប្រសិទ្ធភាពនៃសិទ្ធិរបស់ពួកគេក្នុងការស្នើសុំកិច្ចស៊ើបសួរ”។ *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, អនុស្សរណៈ ក.ស.ច.ស ទៅកាន់ក្រុមមេធាវីការពារក្តី, ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨, ទំព័រទី២។

១៥. មុខងារនៃអំណាចស៊ើបសួរដាច់មុខ និងដ៏ធំធេងរបស់ ក.ស.ច.ស នេះ គឺដើម្បី "លាតត្រដាងនូវការពិត" ដែលពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានកំណត់នៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា[40]។

## ខ. វិសាលភាពនៃការស៊ើបអង្កេតរបស់តុលាការនិងសកម្មភាពស៊ើបអង្កេត

១៦. វិធាន ៥៥(៥) បានដាក់កាតព្វកិច្ចលើសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើកិច្ចការក្នុង នាមជាអង្គការយុត្តិធម៌ប្រកបដោយអនាគតិ ដោយប្រមូលផ្តុំ និងវាយតម្លៃលើភស្តុតាងដាក់បន្ទុក ព្រមទាំងភស្តុតាងដោះបន្ទុក ដោយមានវិសាលភាពដូចគ្នា។ ការប្រើពាក្យបញ្ជារថា "ត្រូវតែ" ចង្អុលបង្ហាញថា ពុំមានឆន្ទានុសិទ្ធិសម្រាប់ ក.ស.ច.ស ពាក់ព័ន្ធនឹងការបំពេញកិច្ចស៊ើបសួរប្រកបដោយអនាគតិ ព្រមទាំងភារៈកិច្ចរបស់ ក.ស.ច.ស ក្នុងការស្រាវជ្រាវ និង លាតត្រដាងដល់ភាគីនូវភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។

១៧. វិធាន ៥៥(២) ដាក់កម្រិតលើវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការដែលធ្វើឡើងដោយ ក.ស.ច.ស។ វិធាននេះចែងថា "ក.ស.ច.ស ត្រូវធ្វើការស៊ើបអង្កេតតែលើអង្គហេតុ ដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬក៏ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមប៉ុណ្ណោះ"។ មាត្រា ២ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ក៏បានដាក់កម្រិតលើសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការនាំយកធ្វើការកាត់ទោសនូវ "អ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ច្បាប់និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជា ដែលត្រូវបានប្រព្រឹត្តនៅក្នុងរយៈពេលចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩" ។

## V. ឧបត្ថម្ភករណ៍

## ក. សំណើសុំនេះចូលនៅក្នុងយុត្តាធិការតាមផ្លូវច្បាប់របស់ ក.ស.ច.ស

[40] វិធាន ៥៥(៥)។

១៨. សូមធ្វើការគូសបញ្ជាក់ថា ក.ស.ច.ស ត្រូវបានផ្តល់យុត្តាធិការដាច់មុខទៅលើកិច្ចស៊ើបសួរតាមផ្លូវតុលាការតាមរយៈកិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង ។ បើសិន ក.ស.ច.ស បដិសេធនូវសំណើសុំអោយបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី នោះមេធាវីការពារក្តីតាមច្បាប់ត្រូវបានហាមឃាត់មិនអោយធ្វើការងារនោះដោយខ្លួនឯង ហើយបំពេញកិច្ចស៊ើបសួរនោះដោយខ្លួនឯងឡើយ[41]។ មានតែជំរើសមួយគត់ប៉ុណ្ណោះសម្រាប់មេធាវីការពារក្តី គឺត្រូវប្តឹងឧទ្ធរណ៍នឹងការបដិសេធបែបនេះតាមវិធាន ៧៤(៣)(ខ) ។ ថ្វីបើ ក.ស.ច.ស មានដែនកំណត់ក្នុងការស៊ើបសួរត្រឹមតែអង្គហេតុនានាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ តាមវិធាន ៥៥(២) និង មាត្រា ២ នៃច្បាប់បង្កើត អ.វ.ត.ក ក្តី ក៏បញ្ញត្តិទាំងនេះ អាចមិនត្រូវយកជាធ្វើសំអាងដោយ ក.ស.ច.ស ឬ ក.ស.ព ដើម្បីដាក់កម្រិតនូវវិសាលភាពពេលវេលានៃអង្គហេតុនានា ដែលអាចជាប់ពាក់ព័ន្ធដល់ការលាតត្រដាងបង្ហាញការពិត ចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហេតុដូច្នេះ អង្គហេតុពាក់ព័ន្ធអាចមាននៅមុន ឬ នៅក្រោយរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[42]។

១៩. ក.ស.ច.ស គួរតែបានបកស្រាយនូវយុត្តាធិការតាមផ្លូវច្បាប់របស់ខ្លួននេះអោយបានទូលំទូលាយ ខណៈដែលវាស្ថិតនៅក្នុងថេរៈវេលាសមស្របនៃការបកស្រាយ ដើម្បីធ្វើការវាយតម្លៃថា តើត្រូវផ្តល់តាមសំណើសុំអោយបំពេញកិច្ចស៊ើបសួរដោយគូភាគីដែរឬអត់ ។ ដូចដែលបានអះអាងនៅទីនេះ ការបកស្រាយទូលំទូលាយបែបនេះ គឺជាហេតុផលដែលអាចទទួលយកបាននៅពេលដែលកម្មវត្ថុនោះ គឺមានលក្ខណៈធម្មជាតិជាប់មកជាមួយនឹងសុចរិតភាពនៃកាតព្វកិច្ចស៊ើបសួររបស់ ក.ស.ច.ស ដើម្បីដាក់ចេញនូវការធ្វើវិភាគមួយដែលមានយុត្តិធម៌ មានតុល្យភាពនិងមិនលំអៀងយ៉ាងហ្មត់ចត់ ឬគ្មានពាក់ព័ន្ធអំពើពុករលួយ ទៅលើភស្តុតាង (ដាក់បន្ទុក និងដោះបន្ទុក) ដែលជាប់ពាក់ព័ន្ធនឹងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

២០. ផ្សេងពីការជ្រើសរើសនូវវិធីសាស្ត្រដែលសមរម្យ និងសមហេតុសមផល ដើម្បីដាក់កម្រិតលើយុត្តាធិការស៊ើបសួររបស់ខ្លួន ក.ស.ច.ស ជ្រើសយកការយល់ឃើញមួយដែលសាមញ្ញ និងដែល

---

[41] *រឿងក្តីរបស់ នួន ជា,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស អនុស្សរណៈរបស់ ក.ស.ច.ស មកមេធាវីការពារក្តី ចុះថ្ងៃទី ១០ មករា ២០០៨ ទំព័រ ២។

[42] *សូមមើល រឿងក្តីរបស់ អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើរបស់លោក អៀង សារី សុំអោយបំពេញកិច្ចស៊ើបសួរលើកទីមួយ ចុះថ្ងៃទី ២០ មីនា ២០០៩ កថាខណ្ឌ ២-៨ ។

មានដែនកំណត់ក្លែងក្លាយ ចំពោះអ្វីដែលបង្កើតបានជា "ការលាតត្រដាងបង្ហាញការពិត" នៅក្នុងបរិបទនៃវិធាន ៥៥(៥) ។ ក្នុងការធ្វើយុត្តិកម្មចំពោះការបកស្រាយរបស់ខ្លួនដែលមានចេតនាពុំប្រមើលមើលវែងឆ្ងាយ ទៅលើអំណាចស៊ើបសួររបស់ខ្លួនតាមវិធាន ៥៥(៥) ក.ស.ច.ស បានធ្វើភ័ន្តច្រលំដែលមិនប៉ិនប្រសប់អំពីប្រភេទនៃសំណើសុំនេះ អញ្ចឹងហើយទើបសំណើសុំនេះស្ថិតនៅក្រៅវិសាលភាពនៃការបកស្រាយនេះ ។

២១. ដីកាសម្រេចរបស់ ក.ស.ច.ស បានកត់សម្គាល់ថា មេធាវីការពារក្តីបានស្នើអោយ ក.ស.ច.ស ប្រមូល "ព័ត៌មានដែលនាំដល់ការលាតត្រដាងបង្ហាញការពិតអំពីតុលាការនេះ[43]" ហើយ "បង្ហាញនូវធាតុផ្សំពុករលួយនៅក្នុងតុលាការនេះ[44]"។ ដូច្នេះហើយទើប ក.ស.ច.ស ចាប់ផ្តើមបដិសេធនូវសំណើសុំ នេះដោយឈរលើមូលដ្ឋានថា អំណាចស៊ើបសួរអង្គហេតុនានាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសបន្ថែមដោយ ក.ស.ព "មិនអាចលាតសន្ធឹងដល់ការលាតត្រដាងបង្ហាញការពិត *"អំពីតុលាការនេះ"* ដូចដែលមេធាវីការពារក្តីប្រាថ្នានោះទេ ដោយសារបញ្ហានេះគឺជាបញ្ហាថ្មីស្រឡាងចំពោះអង្គហេតុដែលគ្របដណ្តប់លើកិច្ចស៊ើបសួររបស់តុលាការបច្ចុប្បន្ននេះ" [45]។ ក.ស.ច.ស យ៉ាងសាមញ្ញបំផុត យល់ច្រលំលើខ្លឹមសារ និងគោលបំណងនៃសំណើសុំនេះ។ មេធាវីការពារក្តី បានធ្វើសំណើសុំនេះមួយផ្នែកសិន នៅពេលដែលព័ត៌មានដែលបានស្នើសុំត្រូវបានផ្តល់មក ទើបខ្លួនអាចវាយតម្លៃថា តើលទ្ធផលក្នុងអំពើពុករលួយដែលគេរាយការណ៍មកនោះ (ដូចដែលទទួលស្គាល់ដោយលោក Knut Rosandhaug ជាអ្នកតំណាងជាន់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិនោះ) ជះឥទ្ធិពលដល់ការសន្និដ្ឋានលើអង្គហេតុដែលត្រូវបានសំរេច ឬនឹងត្រូវបានសំរេចដោយ ក.ស.ច.ស ដើម្បីវាយតម្លៃលើភស្តុតាងដែល ក.ស.ច.ស បានប្រមូលឬវាយតម្លៃ ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ តាមពិត ភស្តុតាងទាក់ទងនឹងការសន្និដ្ឋានលើអង្គហេតុដែលត្រូវបានសម្រេច ឬនឹងត្រូវបានសម្រេចដោយ ក.ស.ច.ស ដើម្បីវាយតម្លៃលើភស្តុតាងដែល ក.ស.ច.ស បានប្រមូលឬវាយតម្លៃ ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺច្បាស់ណាស់ជាភស្តុតាងដោះបន្ទុក (ដែលនឹងមានពណ៌នាលំអិតខាងក្រោម)។ ជាបច្ច័យ សំណើសុំ គឺមិនមែន "ជាបញ្ហា

---

[43] ដីកាសម្រេចរបស់ ក.ស.ច.ស *ដោយយកជាសំអាង* សំណើសុំ កថាខណ្ឌ ១៧ ។

[44] យោងដូចខាងលើ *ដោយយកជាសំអាង* សំណើសុំ កថាខណ្ឌ ២១ ។

[45] យោងដូចខាងលើ កថាខណ្ឌ ១០ ។ (អក្សរទ្រេតមកពីច្បាប់ដើម)

ថ្មីស្រឡាងចំពោះអង្គហេតុ ដែលគ្របដណ្តប់លើកិច្ចស៊ើបសួររបស់តុលាការបច្ចុប្បន្ននេះ[46]" ដូចដែល ក.ស.ច.ស ចោទប្រកាន់នោះឡើយ ។ សំណើសុំនេះគឺមានលក្ខណៈធម្មជាតិជាប់មកជាមួយមួយផ្នែកនៃកិច្ចស៊ើបសួររបស់តុលាការដែលផ្តល់អាណត្តិដោយមាត្រា ២ នៃកិច្ចព្រមព្រៀង និងវិធាន ៥៥(២) ។

## ខ. ព័ត៌មានដែលបានស្នើសុំស្ថិតនៅដោយផ្ទាល់ក្នុងយុត្តាធិការពីកំណើតរបស់ ក.ស.ច.ស ដើម្បីបញ្ញត្តិអំពីភាពត្រឹមត្រូវនៃដំណើរការនីតិវិធីតុលាការ

២២. ដើម្បីជាប្រយោជន៍នៃការជជែកវែកញែកសូមសន្មតថា សំណើសុំនេះ ស្ថិតនៅក្រៅយុត្តាធិការរបស់ ក.ស.ច.ស តាមមាត្រា ២ និង វិធាន ៥៥(២) ប៉ុន្តែទោះយ៉ាងនេះក៏ដោយ ក.ស.ច.ស គឺមានកាតព្វកិច្ចពីកំណើតបន្ថែមទៀត ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីតុលាការគឺមានភាពយុត្តិធម៌ និងឥតលំអៀង ។ នេះគឺជាគោលបំណងទី ២ នៃ សំណើសុំនេះ គឺថាត្រូវពិនិត្យមើលថា តើព័ត៌មានដែលបានស្នើសុំជះឥទ្ធិពលអ្វីខ្លះមកលើភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចស៊ើបសួររបស់តុលាការដោយខ្លួនឯង ។

២៣. ដីកាសម្រេចរបស់ ក.ស.ច.ស នេះទទួលស្គាល់ថា "សហចៅក្រមស៊ើបអង្កេតត្រូវតែធានាថាគ្រប់ចំណុចនៃ នីតិវិធីដែលកំពុងដំណើរការនាពេលបច្ចុប្បន្ននៅក្នុង អ.វ.ត.ក មិនត្រូវបានគេមិនគោរព[47]" ។ ការណ៍នេះឆ្លុះបញ្ចាំងពីការយល់ឃើញរបស់ អង្គបុរេជំនុំជម្រះ នៅក្នុងការសម្រេចលើភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ បានទទួលស្គាល់ថា សិទ្ធិដ៏ទូលំទូលាយអាចមានច្រើនជាងអ្វីដែលមានរាយរាប់ជាក់លាក់នៅក្នុង វិធាន ៧៤(៣) ដោយសារភាពចាំបាច់ដើម្បី "ធានាថានីតិវិធីនាដំណាក់កាលស៊ើបសួរមានភាពត្រឹមត្រូវ" [48]។

---

[46] យោងដូចខាងលើ ។

[47] យោងដូចខាងលើ កថាខណ្ឌ ១២ ។

[48] *រឿងក្តីរបស់ អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ កុម្ភៈ ២០០៩ កថាខណ្ឌ ៣១ ("សាលដីការឿងការបកប្រែរបស់ អៀង សារី") ។ *រឿងក្តីរបស់ អៀង សារី,* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អបជ១៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ កុម្ភៈ ២០០៩ កថខណ្ឌ ២៨ ។

២៤. ទ្រឹស្តីយុត្តាធិការកំណើតដើម្បីធានាភាពត្រឹមត្រូវនៃដំណើរការនីតិវិធី ត្រូវបានពន្យល់បន្ថែមដោយអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការអតីតយូហ្គោស្លាវី ("អង្គជំនុំជម្រះតុលាការកំពូលរបស់ ICTY") នៅក្នុងរឿងក្តី *Delalić* ។ អង្គជំនុំជម្រះនេះបានយល់ឃើញថា៖

> "អំណាចពីកំណើតរបស់អង្គជំនុំជម្រះមាន មានដើមកំណើតមកពីមុខងារតុលាការរបស់ខ្លួន និងមកពីបញ្ញត្តិនានានៃមាត្រា ២០ [អង្គជំនុំជម្រះត្រូវធានាថា ការជំនុំជម្រះសេចក្តីមួយត្រូវមានយុត្តិធម៌ និងឆាប់រហ័ស ហើយនីតិវិធីនានាត្រូវធ្វើឡើងអោយស្របនឹងវិធាននីតិវិធីនិងភស្តុតាង RPE ដោយគោរពយ៉ាងពេញលេញបរិបូរណ៍នូវសិទ្ធិរបស់ជនជាប់ចោទ] និង មាត្រា ២១ [សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ និងជាសាធារណៈ] នៃច្បាប់លក្ខន្តិកៈរបស់ខ្លួន ដើម្បីគ្រប់គ្រងដំណើរការនីតិវិធីក្នុងវិធីមួយដើម្បីធានាថា មានយុត្តិធម៌ និង ជាពិសេសទាក់ទងនឹងការអនុវត្ត ដំណើរការជំនុំជម្រះសេចក្តីត្រូវប្រព្រឹត្តទៅដោយត្រឹមត្រូវ និងឆាប់រហ័ស" [49]។

២៥. ស្រដៀងគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលរបស់ICTY នៅក្នុងរឿងក្តី *Blagojević* បានយល់ឃើញថា "មានតែអំណាចពីកំណើតតែមួយគត់ប៉ុណ្ណោះដែលអង្គជំនុំជម្រះមួយមាន គឺដើម្បីធានាថា ការជំនុំជម្រះសេចក្តីជនជាប់ជាប់មានយុត្តិធម៌" [50]។ ទ្រឹស្តីនេះត្រូវបានប្រើប្រាស់ដោយតុលាការជាច្រើនទាំងនៅតុលាការអន្តរជាតិ *ចំពោះកិច្ច* (*ad hoc*) នានាដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី[51] និង រ៉ាន់ដា[52] និងនៅតុលាការព្រហ្មទណ្ឌ

---

[49] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Delalić et al សំណុំរឿងលេខ IT-96-21សេចក្តីសម្រេចលើពាក្យសុំដកខ្លួនចេញជាមេធាវីការពារក្តីដោយសារបញ្ហាទំនាស់ផលប្រយោជន៍ ចុះថ្ងៃទី ២៤ មិថុនា ១៩៩៩ ។

[50] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Blagojević* សំណុំរឿងលេខ IT-02-60-AR73.4 សេចក្តីសំអាងហេតុជាសាធារណៈ និងដែលដកចេញផ្នែកសម្ងាត់ចេញចំពោះសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Blagojević ដើម្បីដាក់ជំនួសក្រុមមេធាវីការពារក្តីរបស់គាត់ ចុះថ្ងៃទី ៧ វិច្ឆិកា ២០០៣ កថាខណ្ឌ ៧ ។

[51] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1សាលដីកាលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ កក្កដា ១៩៩៩ កថាខណ្ឌ ៣២២។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tadić* សំណុំរឿងលេខ IT-94-1 សាលក្រមលើការចោទប្រកាន់អំពីការប្រមាថតុលាការប្រឆាំងនឹងមេធាវីការពារក្តីកាលពីមុន *Milan Vujin* ចុះថ្ងៃទី ៣១ មករា ២០០០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac et al* សំណុំរឿងលេខ IT-96-23 សេចក្តីសម្រេចលើសំណើសុំរបស់ជនជាប់ចោទ *R. Kovac* ដើម្បីអនុញ្ញាតអោយលោក *M. Vujin* មានវត្តមានជាសហមេធាវីការពារក្តីដោយមិនគិតកំរៃ (pro-bono) ចុះថ្ងៃទី ១៤ មីនា ២០០០ ។ *សូមមើលផងដែរ* អត្ថបទរបស់ M. Buteau and G. Oosthuizen ដែលមានចំណងជើងថា *នៅពេលដែលច្បាប់លក្ខន្តិកៈ និង វិធានមិនមានចែង៖ អំណាចពីកំណើតរបស់តុលាការ* នៅក្នុង R. MAY, D. TOLBERT, J. HOCKING, K. ROBERTS, B. BING JIA, D. MUNDIS AND G. OOSTHUIZEN (EDS.), អត្ថបទស្រាវជ្រាវដែលទទួលបានការកោតសរសើរ (ESSAYS IN HONOUR)

អន្តរជាតិ[53]។ នៅក្នុងន័យសាមញ្ញ ទ្រឹស្តីនេះអនុញ្ញាតអោយតុលាការប្រើប្រាស់នូវយុត្តាធិការពីកំណើតរបស់ខ្លួន ដើម្បីប្រើអំណាចដែល "កាន់តែទូលំទូលាយ និងពេញទំហឹងឡើង ជ្រាបចូលទៅក្នុងរាល់កិច្ចដំណើរការនីតិវិធីនៅគ្រប់ដំណាក់កាល និងបំពេញនូវកង្វះខាតនានាបន្សល់ទុកដោយវិធាននីតិវិធី" [54]។

២៦. នៅក្នុងសេចក្តីសម្រេចដែលស្រដៀងគ្នានឹងដល់រឿងក្តីបច្ចុប្បន្ននេះ នៅតុលាការ ICTR ក្នុងរឿងក្តី *Ntabakuze* និង *Kabiligi*[55] បានអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តីសុំអោយលាតត្រដាងនូវរបាយការណ៍របស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ១ សីហា ១៩៩៧ ដែលស្ថិតក្នុងការកាន់កាប់របស់ប្រធានតុលាការ ICTR និងបិទស្លាកបោះត្រា (ត្រូវបានប្រគល់ជូនប្រធានតុលាការនេះដោយរដ្ឋអាជ្ញាសម្រាប់គោលបំណងនៃការជំនុំជម្រះលើពាក្យសុំនេះ)។ អង្គជំនុំជម្រះបានយល់ឃើញថា ចាប់តាំងពីរបាយការណ៍នេះមិនបានស្ថិតក្នុងការកាន់កាប់របស់រដ្ឋអាជ្ញា វិធាន ៦៦(ខ) (ដែលចែងអំពីការលាតត្រដាងនូវឯកសារភស្តុតាងដោយរដ្ឋអាជ្ញា) និង វិធាន ៦៨ (ដែលពិពណ៌នាពីការលាតត្រដាងនូវឯកសារភស្តុតាងដោះបន្ទុក) មិនអនុវត្តបានឡើយ។ យ៉ាងណាក៏ដោយ

---

ស្តីពីនីតិវិធីនិងភស្តុតាងនៅ GABRIELLE KIRK MCDONALD (ទីក្រុង ឡាអេះ ច្បាប់អន្តរជាតិ Kluwer ២០០១) ទំព័រ ៦៥-៨១ ដែលធ្វើការពិភាក្សាពេញលេញទៅលើទំហំនៃអំណាចពីកំណើតនេះ ។

[52] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Nyiramasukuko and Ntahobali* សំណុំរឿងលេខ ICTR-97-21-T សេចក្តីសម្រេចលើពាក្យសុំរបស់ Ntahobali ចំពោះការដកខ្លួនចេញរបស់មេធាវីការពារក្តី ចុះថ្ងៃទី ២២ មិថុនា ២០០១ កថាខណ្ឌ ២០។ *សូមមើលផងដែរ* អត្ថបទរបស់ Louise Symons ស្តីពី អំណាចពីកំណើតរបស់តុលាការ ICTY និង ICTR សៀវភៅ *InternationalCriminal Law Review* 3 ទំព័រ ៣៦៩-៤០៤ ឆ្នាំ ២០០៣ ។

[53] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Lubanga សំណុំរឿងលេខ , ICC-01/04-01/06-1401 សេចក្តីសម្រេចលើលទ្ធផលនៃការមិនលាតត្រដាងនូវភស្តុតាងដោះបន្ទុកដែលគ្របដណ្តប់ដោយ មាត្រា ៥៤(៣)(ង) នៃកិច្ចព្រមព្រៀង និងការអនុវត្តនូវការផ្អាកនីតិវិធីចោទប្រកាន់លើជនជាប់ចោទ ជាមួយគ្នានឹងបញ្ហាជាក់លាក់ដែលបានលើកឡើងនៅសន្និសិទ្ធស្តីពីឋានៈ (status confrerence) កាលពីថ្ងៃទី ១០ មិថុនា ២០០៨ ចុះថ្ងៃទី ១៣ មិថុនា ២០០៨ កថាខណ្ឌ ៥៣-៥៤ ។

[54] អត្ថបទរបស់ I. Jacob ស្តីពី *យុត្តាធិការពីកំណើតរបស់តុលាការ* (ឆ្នាំ ១៩៧០) ២៣ បញ្ហាច្បាប់ពេលបច្ចុប្បន្ន ទំព័រ ៥០-៥១។ *សូមមើលផងដែរ* អត្ថបទរបស់ WILLIAM A. SCHABAS ស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់អង្គការសហប្រជាជាតិ៖ តុលាការសម្រាប់អតីតយូហ្គោស្លាវី សម្រាប់រ៉្វាន់ដា និងសម្រាប់សៀរ៉ាឡេអូន (Cambridge ឆ្នាំ ២០០៦) ទំព័រ ១១៥ បានពន្យល់ថា "អំណាចពីកំណើតត្រូវបានគេយកជាសំអាងថាជាយុត្តិកម្មចំពោះការងាកចេញពីវិធាននីតិវិធីនិងភស្តុតាង RPE"។

[55] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ntabakuze និង Kabiligi* សំណុំរឿងលេខ , ICTR-96-34-I សេចក្តីសម្រេចលើពាក្យសុំរបស់ Kabiligi សុំអោយស៊ើបអង្កេត និងលាតត្រដាងភស្តុតាង ចុះថ្ងៃទី ៨ មិថុនា ២០០០ (សេចក្តីសម្រេចករណី *Ntabakuze និង Kabiligi*)។

អង្គជំនុំជម្រះ បានរកឃើញថា នេះជាប្រយោជន៍នៃយុត្តិធម៌ដើម្បីប្រើប្រាស់នូវអំណាចពីកំណើត របស់អង្គជំនុំជម្រះ និងធ្វើអោយរបាយការណ៍នេះអាចរកបានដោយភាគី[56]។ ថ្វីបើ អង្គជំនុំជម្រះ បានអះអាងថាកាលៈទេសៈទាំងនេះគឺជាករណីលើកលែង ហើយថាសកម្មភាពរបស់ខ្លួនមិនអាច ត្រូវបានគេពិចារណាថាបានបង្កើតនូវយុត្តិសាស្ត្រ[57]ក៏ដោយ របាយការណ៍នេះត្រូវបានប្រគល់ជូន ក្រុមមេធាវីការពារក្តីចំនួនពីរក្រុមផ្សេងទៀត[58] ។ នេះចង្អុលបង្ហាញថា <u>កាតព្វកិច្ចពីកំណើតដើម្បី ធានាកិច្ចដំណើរការនីតិវិធី មិនមែនជាកាតព្វកិច្ចដែលអាចគ្រាន់តែត្រូវបានគេប្រើប្រាស់នៅក្នុង កាលៈទេសៈលើកលែងប៉ុណ្ណោះទេ ប៉ុន្តែវាជាកាតព្វកិច្ចដែលត្រូវតែគេអាចប្រើប្រាស់នៅក្នុងគ្រប់ រឿងក្តី</u>។

២៧. ក្នុងការអនុវត្ត កាតព្វកិច្ចពីកំណើតនេះមានន័យថា ចៅក្រម ឬអង្គជំនុំជម្រះណាមួយដែលទទួល ខុសត្រូវក្នុងរឿងក្តីមួយ ទោះដោយតាមសំណើសុំរបស់ភាគីណាមួយ ឬ ដោយសេចក្តីផ្តួចផ្តើម របស់ខ្លួន (*proprio motu*) ត្រូវតែចាត់វាល់វិធានដែលអាចមាននានាដើម្បីធានាថា កិច្ចដំណើរ ការនីតិវិធីមានភាពត្រឹមត្រូវ។ បើសិនមានភស្តុតាង (indicia) ណាមួយ ដែលភាពត្រឹមត្រូវនៃកិច្ច ដំណើរការនីតិវិធីត្រូវអន្តរាយដោយតាមវិធីណាមួយ ចៅក្រម ឬអង្គជំនុំជម្រះ ត្រូវតែធ្វើអ្វីៗទាំង អស់ដែលខ្លួនអាចធ្វើបាន ដើម្បីធ្វើអោយប្រាកដខ្លួនឯងថា ករណីនេះមិនកើតមានឡើងចំពោះខ្លួន ឡើយ។

២៨. ផលប៉ះពាល់នៃអំពើពុករលួយមកលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធីតុលាការ ត្រូវបានទទួល យកដោយតុលាការកំពូលរបស់សហរដ្ឋអាមេរិច នៅក្នុងរឿងក្តី *Bracy v. Gramley* ។ នៅទី នេះ តុលាការកំពូលអាមេរិច បានអនុញ្ញាតតាមសំណើរបស់អ្នកដាក់សំណើសុំអោយលាតត្រដាង នូវឯកសារទាក់ទងនឹងអំពើពុករលួយរបស់តុលាការ ដោយត្រូវបង្ហាញនូវ "មូលហេតុត្រឹមត្រូវតាម

[56] យោងដូចខាងលើ កថាខណ្ឌ ១៤-១៦ ។

[57] យោងដូចខាងលើ កថាខណ្ឌ ១៧ ។

[58] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Imanishimwe* សំណុំរឿងលេខ , ICTR-99-46-I សេចក្តីសម្រេចលើពាក្យសុំរបស់ Imanishimwe សុំអោយធ្វើវិសោធនកម្មលើដីកាចោទប្រកាន់ និង ការលាតត្រដាង ចុះថ្ងៃទី ២៣ សីហា ២០០០ ។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Samanza* សំណុំរឿងលេខ ICTR-97-20-I សេចក្តីសម្រេចលើពាក្យសុំរបស់ *Semanza* សុំអោយចេញដីកា កោះ ការយកចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ (Deposition) និងការលាតត្រដាង ចុះថ្ងៃទី ២០ តុលា ២០០០ ។

ច្បាប់ (Good Cause)" ថា ការចោទប្រកាន់ពីអំពើពុករលួយបានជះឥទ្ធិពលដល់ភាពត្រឹមត្រូវនៃការជំនុំជម្រះក្ដីរបស់អ្នកដាក់សំណើ[59]។

២៩. <u>អំពើពុករលួយមិនគ្រាន់តែធ្វើអោយអន្តរាយដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធីតុលាការប៉ុណ្ណោះទេ តែថែមទាំងអន្តរាយដល់សុចរិតរបស់វាទៀត</u>[60] ។ បុព្វកថារបស់អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ("អនុសញ្ញាពុករលួយ") ដែលកម្ពុជាបានផ្ដល់ការយល់ព្រមកាលពីថ្ងៃទី ៥ កញ្ញា ២០០៧ កត់សំគាល់ "ភាពធ្ងន់ធ្ងរនៃបញ្ហា និងការគំរាមកំហែងដែលបង្កដោយអំពើពុករលួយ [...] មកលើនីតិរដ្ឋ[61]"។ នៅក្នុងសេចក្ដីថ្លែងដើមដំបូង (forward) នៃអនុសញ្ញាពុករលួយនេះ អតីតអគ្គលេខាធិការ អ.ស.ប លោក កូហ្វីអាណាន់ បានពណ៌នាពីអំពើពុករលួយថាជា "ជម្ងឺឆ្លងដែលរាតត្បាតបន្តិចម្ដងៗ" ដែល "ឥទ្ធិពលស៊ីរូង (corrosive) របស់វា [...] ធ្វើអោយអន្តរាយដល់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ [...]"[62]។ មាត្រា ១១ នៃអនុសញ្ញាពុករលួយដដែលនេះពន្យល់ថា៖

> "ដោយចងចាំក្នុងចិត្តថា ឯករាជ្យភាពរបស់តុលាការ និងភាពជាសារវ័ន្តនៃមុខងាររបស់តុលាការក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ រដ្ឋជាភាគីនីមួយ ដោយអនុលោមទៅតាមគោលការណ៍ជាសារវ័ន្តនៃប្រព័ន្ធច្បាប់របស់ខ្លួន និង ដោយមិនធ្វើអោយខូចខាតដល់

---

[59] Warden (96-6133), 520 U.S. 899 (1997) ។ គួរអោយកត់សម្គាល់ថា នៅពេលអ្នកដាក់ពាក្យសុំនៅក្នុងរឿងក្ដី *Bracy v. Gramley* ត្រូវបានរកឃើញថាមានទោស ហេតុដូច្នេះហើយសិទ្ធិរបស់គាត់ក្នុងការស្រាវជ្រាវរុករកលែងជាស្វ័យប្រវត្តិទៀតហើយ។ គាត់ចាំបាច់ត្រូវបង្ហាញនូវ "មូលហេតុត្រឹមត្រូវតាមច្បាប់" ដើម្បីធ្វើសំណើសុំអោយលាតត្រដាងភស្តុតាង។ ផ្ទុយទៅវិញ ពុំត្រូវការឲ្យមាន "មូលហេតុត្រឹមត្រូវតាមច្បាប់" បែបនេះនៅក្នុងដំណាក់កាលស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញនោះទេ។ ការលាតត្រដាងនូវព័ត៌មានគឺត្រូវធ្វើឡើងដោយស្វ័យប្រវត្តិ។ *សូមមើលផងដែរ* រឿងក្ដី *Milinienė v. Lithuania* (បណ្ដឹងលេខ ៧៤៣៥៥/០១) សាលក្រមចុះថ្ងៃទី ២៤ មិថុនា ២០០៨ កថាខណ្ឌ ៣៨ ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុប បានសង្កត់ធ្ងន់អំពី "សារៈសំខាន់នៃការជះឥទ្ធិពលយ៉ាងខ្លាំងនៃអំពើពុករលួយរបស់តុលាការទៅលើនីតិរដ្ឋ នៅក្នុងសង្គមប្រជាធិបតេយ្យ"។

[60] អំពើពុករលួយត្រូវបានកំណត់និយមន័យដោយអង្គការតម្លាភាពអន្តរជាតិ ដែលជាអង្គការក្រៅរដ្ឋាភិបាលប្រឆាំងនឹងអំពើពុករលួយឈានមុខគេនៅក្នុងពិភពលោកថាជា " ការរំលោភបំពានលើអំណាចដែលគេប្រគល់ឲ្យដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន"។ ដូចដែលមានការពន្យល់បន្ថែម ទៀតដែរថា អំពើពុករលួយ "ធ្វើឱ្យអន្តរាយដល់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ"សូមមើលគេហទំព័រអង្គការតម្លាភាពអន្តរជាតិសម្រាប់និយមន័យទាំងនេះនៅ http://www.transparency.org/about_us ។

[61] អនុសញ្ញា ទំព័រទី ៥ ត្រូវបានអនុម័តដោយ មហាសន្និបាទអង្គការសហប្រជាជាតិ នៅថ្ងៃទីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៣ (សេចក្ដីសម្រេច ៥៨/៤)។

[62] ឯកសារយោងដដែល ទំព័រ iii. ។

> ឯករាជ្យភាពរបស់តុលាការ ត្រូវចាត់វិធានការដើម្បីពង្រឹងសុចរិតភាព និងបង្កាកុំអោយមានឱកាសមានអំពើពុករលួយក្នុងចំណោមសមាជិករបស់តុលាការ"។

៣០. ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានគូសបញ្ជាក់ដោយស្មើភាពនៅក្នុងប្រសាសន៍របស់ឯកឧត្តមថា៖

> រាជរដ្ឋាភិបាលកម្ពុជាបានដឹងច្បាស់ណាស់ថា អំពើពុក រលួយបានគម្រាមកំហែង [...] ដល់ស្ថាប័នប្រជាធិបតេយ្យនានា និងសិទ្ធិ ព្រមទាំងសេរីភាពជាមូលដ្ឋាន [...]។ វា [ក៏បាន] បណ្តាលឲ្យមានការសម្រេចខុសវិចារណញ្ញាណ[...]ផងដែរ។ បញ្ហាចោទមិននៅត្រង់ថាតើអំពើពុករលួយគួរតែត្រូវបានប្រយុទ្ធប្រឆាំងឬអត់នោះទេ ប៉ុន្តែវានៅត្រង់ថាតើត្រូវធ្វើយ៉ាងដូម្តេច និងដោយមធ្យោបាយអ្វី"[63]។

៣១. ឥទ្ធិពលនៃអំពើពុករលួយមកលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី គឺកាន់តែធ្ងន់ធ្ងរឡើងនៅ អ.វ.ត.ក ជាញឹកញាប់នៅពេលដែលគ្មានការបែងចែកអំណាចអោយបានតឹងរឹងរវាងផ្នែកតុលាការ និងការិយាល័យរដ្ឋបាលនៅ អ.វ.ត.ក ។ ឧទាហរណ៍ ដូចដែលបានលើកឡើងដោយមេធាវីការពារក្តីនៅក្នុងបរិបទដាច់ដោយឡែក ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះជាញឹកញាប់ "លូកដៃចូលក្នុងកិច្ចការដែលបែងចែកដាច់រវាងផ្នែកគ្រប់គ្រងតុលាការ និងអង្គបុរេជំនុំជម្រះ"[64] ។ ថ្វីបើក្រឡាបញ្ជីទាំងនេះ ត្រូវបានជ្រើសរើសមកបំរើការងារដំបូងដោយ "អង្គជំនុំជម្រះ និងការិយាល័យតុលាការ" ក៏ដោយក៏ក្រឡាបញ្ជីទាំងនេះក៏ធ្វើការងារពាក់ព័ន្ធនៅក្នុងកិច្ចការ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ការិយាល័យរដ្ឋបាលផងដែរ[65]។

៣២. ដីកាសម្រេចរបស់ ក.ស.ច.ស មិនមានរៀបរាប់ថា តើ ក.ស.ច.ស ធ្លាប់បានពិចារណាថាព័ត៌មានដែលបានស្នើសុំនេះ អាចជះឥទ្ធិពលដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដែរឬអត់។ យ៉ាងណាក៏ដោយ ដើម្បីធ្វើយុត្តិកម្មនូវការបដិសេធនូវសំណើសុំនេះ ក.ស.ច.ស បានអះអាងថា សំណើសុំនេះគ្រាន់តែបាន "លើកឡើងអំពីការប្រមើលមើលឃើញអំពីផលវិបាកដ៏អាក្រក់ជាយថាហេតុ

---

[63] "ផែនការណ៍សកម្មភាពអភិបាលកិច្ច" សន្ទរកថារបស់ឯកឧត្តម សុខ អាន, ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់, ភ្នំពេញ, ថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០០២។ (គូសបញ្ជាក់បន្ថែម)

[64] *សូមមើល* លិខិតរបស់ អាង ឧត្តម និង Michael G. Karnavas ផ្ញើរទៅប្រធាន អនុប្រធានការិយាល័យរដ្ឋបាលគឺលោក ស៊ាន វិសុទ្ធ និង Knut Rosandhaug ដែលមានចំណងជើងថា "ការធ្វើជ្រៀតជ្រែកមិនត្រឹមត្រូវរបស់ចៅក្រមអង្គបុរេជំនុំជម្រះមកក្នុងមុខងារតុលាការរបស់ផ្នែកគ្រប់គ្រងតុលាការ" ចុះថ្ងៃទី ៣ ធ្នូ ២០០៨ ទំព័រ ៤។

[65] សូមមើល អង្គការលេខរបស់ អ.វ.ត.ក ដែលបានពន្យល់ពីផ្នែកខុសគ្នានៃអង្គភាពនានានៅ អ.វ.ត.ក ។

ណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើងចំពោះដំណើរការនីតិវិធីតុលាការប៉ុណ្ណោះ"[66]។ គេអាចសន្និដ្ឋានបានច្បាស់ថា ក.ស.ច.ស មិនបានពិចារណាថាព័ត៌មានដែលបានស្នើសុំជះឥទ្ធិពលដល់កិច្ចដំណើរការនីតិវិធីឡើយ។ នេះគឺជាការមិនត្រឹមត្រូវទាល់តែសោះ។ ការប្រថុយប្រថានអោយមានអំពើពុករលួយនៅក្នុងផ្នែករដ្ឋបាលតុលាការ ជះឥទ្ធិពលខ្លាំងក្លាមកលើភាពត្រឹមត្រូវនៃដំណើរការនីតិវិធី គឺជាការពិត និងរឹងមាំ ហេតុដូច្នេះហើយភស្តុតាងនានាទាក់ទងនឹងបញ្ហានេះត្រូវតែបានផ្តល់ជូនជនត្រូវចោទ/មេធាវីការពារក្តី។

៣៣. ខណៈពេលដែលគេមិនអាចស្នង់ជម្រៅបានថា ក.ស.ច.ស នៅតែមិនបានដឹងលឺរឿងចោទប្រកាន់អំពើពុករលួយ ដែលត្រូវបានគេរាយការណ៍ស្ទើរតែរៀងរាល់ថ្ងៃនៅក្នុងសារព័ត៌មានកម្ពុជាអស់រយៈកាលជាង ២ឆ្នាំ[67]មកហើយនោះ សំណើសុំ យ៉ាងហោចណាស់គួរផ្តល់ជាការជូនដំណឹងដល់ ក.ស.ច.ស អំពីការចោទប្រកាន់អំពើពុករលួយនៅ អ.វ.ត.ក និងឥទ្ធិពលរបស់អំពើពុករលួយ ដែលអាចមានមកលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ។ សូម្បីតែសន្មតថា សំណើសុំនេះទើបតែជារឿងដំបូងហើយដែល ក.ស.ច.ស បានជ្រាបអំពីបញ្ហានេះ យ៉ាងហោចណាស់ក៏គួរតែមានដីកាសម្រេចថា ក.ស.ច.ស នឹងត្រូវបានគេផ្តល់អោយនូវ របាយការណ៍ OIOS នេះដើម្បីធ្វើអោយ ក.ស.ច.ស ប្រាកដខ្លួនឯងថា ការស៊ើបសួររបស់តុលាការមិនត្រូវបានទទួលការអន្តរាយឡើយ។ ការខកខានមិនបានធ្វើដូច្នេះ បញ្ជាក់យ៉ាងច្បាស់ថា ក.ស.ច.ស បានគិតទុកជាមុនថា នឹងមិនលាតត្រដាងនូវព័ត៌មានដែលបានស្នើសុំឡើយ ទោះបីជាថា ខ្លឹមសារនៃអត្ថបទនោះមានការជាប់ពាក់ព័ន្ធក៏ដោយ។

៣៤. ក.ស.ច.ស បានចាប់អារម្មណ៍លើបញ្ហាជាទម្រង់ ជាជាងខ្លឹមសារ ដើម្បីអោយខ្លួនឯងរួចចាកផុតពីករណីយកិច្ចផ្សេងទៀតដែលត្រូវធានាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែលនឹងលេចចេញពីការចោទប្រកាន់អំពើពុករលួយ។ ហេតុដូច្នេះ វាជាការចាំបាច់ដើម្បីកត់សំគាល់ថា ច្បាប់ និងវិធានពាក់ព័ន្ធដែលគ្រប់គ្រងនូវកាតព្វកិច្ចនានារបស់ ក.ស.ច.ស ត្រូវតែយកជាសំអាង មិនមែនទៅលើការអនុវត្តនូវទម្រង់ការនោះទេ ប៉ុន្តែគោលបំណងដើម្បីបន្តស្វែងរកយុត្តិធម៌[68]។ ជាការងាយ

---

[66] ដីកាសម្រេច របស់ ក.ស.ច.ស ទំព័រ ១២។

[67] *សូមមើល* សំណើសុំ កថាខណ្ឌ ៤ ដល់ ១១ ដែលរបៀបរាប់លំអិតពីអត្ថបទជាច្រើនដែលបានចុះផ្សាយនៅក្នុងកាសែតដឺខេមបូឌៀដេលី និង ភ្នំពេញប៉ុស្ត៍ ទាក់ទងនឹងអំពើពុករលួយនៅ ក.ស.ច.ស ។

[68] *សូមមើល* អត្ថបទរបស់ Eugen Ehrlich ស្តីពី *គោលការណ៍ជាសារវន្តនៃសង្គមសាស្ត្ររបស់ច្បាប់* (Walter L. Moll trans., Harvard University Press, ១៩៣៦)។

ស្រួល ក.ស.ច.ស ប្រាថ្នា "មិនចង់ឃើញ រឿងអាក្រក់ មិនចង់លឺរឿងអាក្រក់ មិនចង់និយាយពីរឿងអាក្រក់" [69]។ តាមពិត ពាក្យពេចន៍ស្រដៀងគ្នាសមហេតុផល អាចអោយសន្និដ្ឋានចេញពីភាពងងឹតងងុលដោយមានចេតនារបស់ ក.ស.ច.ស និង ប្រភេទនៃអំពើដែលអាចចោទប្រកាន់បានតាមរយៈទ្រឹស្តីការទទួលខុសត្រូវរបស់អ្នកដឹកនាំជាន់ខ្ពស់(superior responsibility) ដែលមេបញ្ជាការម្នាក់ដែលមិនអាចមិនអើពើពីព័ត៌មានដែលស្ថិតនៅក្នុងការកាន់កាប់របស់ខ្លួន បង្ខំអោយធ្វើការសន្និដ្ឋានថា បទល្មើសព្រហ្មទណ្ឌមួយចំនួនកំពុងត្រូវបានគេប្រព្រឹត្ត ឬក៏ ហៀបតែនឹងប្រព្រឹត្ត[70] នោះវាមានករណីយកិច្ចវិជ្ជមានមួយដើម្បីចាត់វិធានការអោយមានប្រសិទ្ធិភាព។ នៅក្នុងឧទាហរណ៍បច្ចុប្បន្ន និងដោយប្រឆាំងនឹងភស្តុតាងដ៏ធំធេងនៃអាកប្បកិរិយាពុករលួយនៅក្នុង អ.វ.ត.ក ក.ស.ច.ស មានចេតនាគេចវេសមិនធ្វើទំនាក់ទំនងជាមួយ និងគេចវេសពីការដឹងលឺពីខ្លឹមសារនៃរបាយការណ៍ OIOS ដូច្នេះហើយ ក.ស.ច.ស មិនចាំបាច់ត្រូវចាត់វិធានការអ្វីឡើយ ដែលនេះគឺជាឧទាហរណ៍ដ៏ប្រណិតមួយនៃការបន្តធ្វើល្ងិតល្ងង់ដោយសន្តិវិធី (an exquisite case of maintaining blissful ignorance)។

**គ. សំណើសុំនេះ មិនមានភាពជាក់លាក់គ្រប់គ្រាន់ និងមិនមានរៀបរាប់ថាហេតុអ្វីបានជាព័ត៌មានដែលស្នើសុំ គឺជាភស្តុតាងដោះបន្ទុក ទាក់ទងនឹងអង្គហេតុនានាដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬក៏បានជះឥទ្ធិពលដល់ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី**

៣៥. ដូចដែលមានរៀបរាប់ខាងលើ គោលបំណងនៃសំណើសុំ គឺដើម្បីពិនិត្យមើលថា តើសំណើសុំព័ត៌មានដែលធ្វើអោយលទ្ធផលដែលគេរាយការណ៍អំពីអំពើពុករលួយងាយស្រួលយល់ ជះឥទ្ធិពលដែរឬទេមកលើ៖

---

[69] ពាក្យសាមញ្ញនេះ គឺត្រូវបានគេប្រើប្រាស់ជាពិសេសដើម្បីពិពណ៌នាចំពោះនរណាម្នាក់ដែលមិនចង់អោយខ្លួនឯងប្រឡាក់ប្រឡូសជាមួយនឹងស្ថានការណ៍អ្វីមួយ។

[70] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Delalić et al* សំណុំរឿងលេខ IT-96-21-T សាលក្រម ចុះថ្ងៃទី ១៦ វិច្ឆិកា ១៩៩៨ កថាខណ្ឌ ៣៨៧ ។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Strugar*,សំណុំរឿងលេខ IT-01-42-T សាលក្រម ចុះថ្ងៃទី ៣១ មករា ២០០៥ កថាខណ្ឌ ៤១៦ ។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Halilović* សំណុំរឿងលេខ IT-01-48-T សាលក្រម ចុះថ្ងៃទី ១៦ វិច្ឆិកា ២០០៥ កថាខណ្ឌ ៦៩។

ក. ការសន្និដ្ឋានលើអង្គហេតុដែលត្រូវបានសំរេច ឬនឹងត្រូវបានសំរេចដោយ ក.ស.ច.ស ដើម្បីវាយតម្លៃលើភស្តុតាងដែល ក.ស.ច.ស បានប្រមូលឬវាយតម្លៃ ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង/ឬ

ខ. ភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចស៊ើបសួររបស់តុលាការដោយខ្លួនឯង

៣៦. ដើម្បីអោយសំណើសុំនេះអាចត្រូវបានទទួលការអនុញ្ញាត ទោះបីឈរលើមូលដ្ឋានណាមួយក្នុងចំណោមទាំងពីរ មេធាវីលោក អៀង សារី យល់ស្របថា សំណើសុំនេះត្រូវតែ៖ (១) ជាក់លាក់គ្រប់គ្រាន់ដើម្បីអនុញ្ញាតអោយមានកិច្ចស៊ើបសួរ (ឧទាហរណ៍៖ ត្រូវពន្យល់អោយចំជាក់លាក់កាន់តែប្រសើរថាអ្វីដែលចង់បាន) និង (២) យ៉ាងហោចណាស់ដល់កំរិតមួយដែលផ្តួចផ្តើមចេញពីខ្លួនឯង (Prima facie) បង្កើតអោយមានលក្ខណៈធម្មជាតិដោះបន្ទុកនៃព័ត៌មានដែលបានស្នើសុំ ឬផលប៉ះពាល់របស់វាមកលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី (ឧទាហរណ៍៖ ត្រូវពន្យល់ថាហេតុអ្វី បានត្រូវការ) ។ យោងតាម ក.ស.ច.ស សំណើសុំ នេះគ្រាន់តែបាន "លើកឡើងអំពីការប្រមើលមើលឃើញអំពីផលវិបាកដ៏អាក្រក់ជាយថាហេតុណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើងចំពោះដំណើរការនីតិវិធីតុលាការប៉ុណ្ណោះ"[71]។ ការអះអាងនេះគ្មានមូលដ្ឋានទាល់តែសោះ។ លក្ខណៈវិនិច្ឆ័យទាំងពីរនេះត្រូវបានបំពេញ និងតម្រូវអោយ ក.ស.ច.ស ប្រើប្រាស់នូវយុត្តាធិការរបស់ខ្លួនទាំងកំណត់ដោយច្បាប់ និងទាំងជាប់មកជាមួយកំណើត ដើម្បីផ្តល់ជូននូវព័ត៌មានដែលបានស្នើសុំ។

### ១. សំណើសុំនេះ មានភាពជាក់លាក់គ្រប់គ្រាន់

៣៧. ទោះបីជាអង្គបុរេជំនុំជម្រះបានផ្តល់ការណែនាំអំពីអ្វី ដែលបង្កើតបានជាសំណើសុំអោយបំពេញកិច្ចស៊ើបសួរ ស្របតាមវិធាន ៥៥(១០)[72] ក៏ដោយក៏រហូតមកទល់នឹងពេលនេះ អង្គបុរេជំនុំជម្រះមិនត្រូវបានគេផ្តល់ឲ្យនូវឱកាស ដើម្បីរៀបរាប់ពីកម្រិតនៃភាពជាក់លាក់នៃសំណើសុំអោយបំពេញកិច្ចស៊ើបសួរនៅឡើយទេ។ ដោយហេតុនេះ ការណែនាំដ៏មានប្រយោជន៍អំពីកម្រិតនៃភាពជាក់លាក់ដែលគេតម្រូវ អាចត្រូវបានផ្តល់អោយដោយយុត្តិសាស្ត្ររបស់តុលាការ ICTY និង តុលាការ ICTR ពាក់ព័ន្ធនឹងសំណើសុំឲ្យលាតត្រដាងឯកសារ។ ខណៈពេលដែលនៅឯតុលាការអន្តរជាតិ *ចំពោះកិច្ច* (*ad hoc*) ទាំងនេះ ដែលរដ្ឋអាជ្ញាមានការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងការដឹកនាំការ

---

[71] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១២។

[72] សេចក្តីសម្រេចលើកការបកប្រែរបស់លោក អៀង សារី, កថាខណ្ឌទី២៣។

ស៊ើបអង្កេត មិនមែនទៅក្រុមស៊ើបអង្កេតនោះ សំណើសុំឲ្យមានការលាតត្រដាងឯកសារពិសេសណាមួយដែលត្រូវបានដាក់ជូនរដ្ឋអាជ្ញានៅតុលាការទាំងនោះ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនៅអង្គជំនុំជម្រះវិសាមញ្ញដូច្នេះដែរ ដោយបានស្នើសុំឲ្យមានការលាតត្រដាងនូវពត៌មានពិសេសណាមួយ។

៣៨. នៅពេលស្នើសុំភស្តុតាងដោះបន្ទុកពីរដ្ឋអាជ្ញា ការពារក្តីនៅចំពោះមុខតុលាការ ICTY មិនត្រូវបានតម្រូវអោយស្នើសុំជាក់លាក់ខ្លាំងពេក ដូចជាត្រូវកំណត់អត្តសញ្ញាណអោយបានច្បាស់លាស់ចំពោះឯកសារណាដែលត្រូវធ្វើការលាតត្រដាងនោះទេ[73]។ យ៉ាងហោចណាស់ សំណើសុំត្រូវ "ជាក់លាក់គ្រប់គ្រាន់ទាក់ទងទៅនឹងលក្ខណៈធម្មជាតិនៃភស្តុតាងដែលស្នើសុំ" [74]។ លក្ខណៈវិនិច្ឆ័យទាំងនេះត្រូវបានបំពេញនៅក្នុងរឿងក្តីថ្មីៗនេះដោយសារមូលហេតុមួយចំនួនដូចតទៅ។ <u>ព័ត៌មានដែលបានស្នើសុំដោយជនត្រូវចោទ/មេធាវីការពារក្តី គឺត្រូវបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់លាស់ថាជា៖ (១) លទ្ធផលនៃការស៊ើបអង្កេតរបស់ OIOS (២) រាល់លិខិតឆ្លើយឆ្លងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការស៊ើបអង្កេតរបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង OIOS (៣) ព័ត៌មានទាំងឡាយលើកឡើង អំពីអំពើពុករលួយជាស្ថាប័នដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុននៅ អ.វ.ត.ក</u>។ ទាំងនេះគឺត្រូវបានបង្ហាញរៀបរាប់យ៉ាងជាក់ច្បាស់នៅក្នុងផ្នែក "សំណូមពរ" នៃសំណើសុំនេះ[75]។ សំណើសុំនេះ គឺដើម្បីសុំព័ត៌មានជាក់លាក់ទាក់ទងនឹងរបាយការណ៍ដែលត្រូវបានរៀបចំដោយការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ OIOS ទៅលើអំពើពុករលួយនៅ អ.វ.ត.ក ។ ផ្អែកពីការកំណត់លក្ខណៈនៃសំណើសុំនេះដោយ ក.ស.ច.ស សំណើសុំនេះមិនមែនជាសំណើសុំអោយបំពេញកិច្ចស៊ើបសួរ

---

[73] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Blaškić,* សំណុំរឿងលេខ IT-95-14-A, សេចក្តីសម្រេចលើញត្តិរបស់អ្នកឧទ្ធរណ៍ សម្រាប់ការផលិតសម្ភារៈ ការព្យួរ ឬការពន្យាថិរវេលា នៃការកំណត់កាលបរិច្ឆេទសង្ខេប និងការដាក់ឯកសារបន្ថែម, ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២000, កថាខណ្ឌទី៤0 ។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Rutaganda,* សំណុំរឿងលេខICTR-96-3-A, សេចក្តីសម្រេចលើញត្តិការពារបន្ទាន់ ស្តីពីការបង្ហាញ និងការទទួលយកភស្តុតាងបន្ថែម និងដីកាកំណត់កាលបរិច្ឆេទសវនាការ, ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២00២។

[74] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tihomir Blaskić* សំណុំរឿងលេខ IT-95-14-AR108*bis* A. Ch សាលក្រមលើសំណើសុំរបស់សាធារណៈរដ្ឋក្រូអាតដើម្បីពិនិត្យឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ II ថ្ងៃទី១៨ កក្កដា ១៩៩៧ ចុះថ្ងៃទី ២0 តុលា ១៩៩៧ កថាខណ្ឌ ៣២ ។

[75] សំណើសុំ ទំព័រ ១៤ ។

ទៅលើការចោទប្រកាន់អំពើពុករលួយនៅតុលាការ និងមិនមែនជាសំណើសុំទូទៅមួយដើម្បីលាតត្រដាងការពិតអំពីតុលាការនេះឡើយ។ ភាពជាក់លាក់នៃសំណើសុំនេះត្រូវបានមើលរំលងទាំងស្រុងដោយ ក.ស.ច.ស ។

**២. សំណើបានពន្យល់ថា ហេតុអ្វីបានជាព័ត៌មានដែលបានស្នើសុំ គឺជាព័ត៌មានដោះបន្ទុក ឬ ប៉ះពាល់ដល់ដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌**

**ក. ភស្តុតាងពីអំពើពុករលួយនៅ អ.វ.ត.ក អាចប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចពិតប្រាកដ ដែលត្រូវបានសម្រេច ឬ សេចក្តីសម្រេចដែលត្រូវតែដោយ ក.ស.ច.ស ហើយអាស្រ័យហេតុនេះ វាជាភស្តុតាងដោះបន្ទុក**

៣៩. សំណើចែងយ៉ាងទូលំទូលាយថា ហេតុអ្វីអំពើពុករលួយនៅក្នុងការិយាល័យរដ្ឋបាល អាចប៉ះពាល់ដល់ការធ្វើសេចក្តីសម្រេចដោយ ក.ស.ច.ស[76]។ ការចោទប្រកាន់ទាំងនោះមិនត្រូវដាក់កម្រិតត្រឹមតែ "ការប្រមើលមើលស្មានអំពីផលវិបាកដ៏អាក្រក់ជាថាយហេតុណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើង ចំពោះដំណើរការនីតិវិធិតែប៉ុណ្ណោះទេ"[77] ប៉ុន្តែ គឺជាការបកស្រាយ

---

[76] សំណើ កថាខណ្ឌ ១៩ ។ ផលប៉ះពាល់ដែលអាចមានទៅលើការធ្វើសេចក្តីសម្រេចពិតប្រាកដដោយ ក.ស.ច.ស មានដូចតទៅ៖ (១) មន្ត្រីច្បាប់ អ្នកស៊ើបអង្កេត ឬក្រឡាបញ្ជី ដែលបានទទួលប្រតិភូកម្មអំណាចតុលាការមួយផ្នែកណានោះ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យរដ្ឋបាល អាចទទួលយកដោយចេតនានូវសេចក្តីសម្រេចមិនត្រឹមត្រូវ ដែលផ្ទុយទៅនឹងផលប្រយោជន៍របស់មេធាវីការពារក្តី ដូចជា ការផ្តល់យោបល់ជំទាស់ទៅនឹងសំណើស្របច្បាប់ស្នើសុំឱ្យបើកកិច្ចស៊ើបសួរ ការខកខានមិនបានស្វែងរកភស្តុតាងដោះបន្ទុកពីប្រភពដែលបានដឹង ឬ ការសហការជាមួយភាគីរដ្ឋប្បវេណី ដែលវៀចវេរ, (២) មន្ត្រីសំណុំរឿងអាចប្រឌិត កែប្រែ ធ្វើឱ្យច្រលំ និង/ឬ បំផ្លាញភស្តុតាង ដែលជាប្រយោជន៍ដល់មេធាវីការពារ, (៣)បុគ្គលិកផ្នែកបច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មានវិទ្យា អាចលួចមើល និងបញ្ជូនព័ត៌មានអេឡិចត្រូនិកសម្ងាត់ ដូចជា ការណែនាំរបស់កូនក្តី ឬទិន្នផលការងាររបស់មេធាវីការពារទៅឱ្យ ក.ស.ព ឬបដិភាគីផ្សេងទៀត, (៤) អ្នកបកប្រែសំណេរ និងអ្នកបកប្រែផ្ទាល់មាត់ អាចលុបចោលភស្តុតាងដោះបន្ទុកពីឯកសារដែលបានបកប្រែជាសំណេរ ឬបកប្រែសក្ខីកម្មដែលមានប្រយោជន៍ដល់មេធាវីការពារឱ្យខុសដោយចេតនា, (៥) អ្នកចាត់ចែងសាក្សីអាចណែនាំមិនត្រឹមត្រូវ ឬមានចេតនាប្រើឥទ្ធិពលទៅលើសាក្សី និងអ្នកជំនាញ ដើម្បីឱ្យផ្តល់សក្ខីកម្មក្លែងក្លាយប្រឆាំងនឹងមេធាវីការពារ និង (៦) សន្តិសុខ អ្នកបោសសំអាត ឬបុគ្គលិកកំទេចកាកសំណល់ ដែលអ្នកទាំងអស់នេះអាចមានលទ្ធភាពច្រើនក្នុងការទទួលបានឯកសារសម្ងាត់របស់មេធាវីការពារនោះ អាចអាន ឬថតចម្លងឯកសារ និងបញ្ជូនព័ត៌មានរសើបទៅឱ្យអ្នកដែលមិនមានសិទ្ធិមើលព័ត៌មាននេះ។

[77] ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១២ ។

ការពិតប្រកបដោយសមហេតុផល និង ផលប៉ះពាល់បច្ចុប្បន្នទៅលើការធ្វើសេចក្តីសម្រេចពិតប្រាកដដោយ ក.ស.ច.ស ទៅលើអំពើពុករលួយនៅក្នុងការិយាល័យរដ្ឋបាល។

៤០. មូលហេតុគ្រប់គ្រាន់បានធ្វើយុត្តិកម្មទៅលើលក្ខណៈដោះបន្ទុករបស់ព័ត៌មានដែលបានស្នើសុំនោះ គឺត្រូវបានគាំទ្រដោយអត្ថបទមួយរបស់ The Economist ដែលចោទប្រកាន់ថា អំពើពុករលួយបានសាយភាយទៅដល់ "បុគ្គលិកជំនួយការច្បាប់កម្ពុជានៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត និង សហព្រះរាជអាជ្ញា"។ម្យ៉ាងវិញទៀត វាមិនគ្រាន់តែជាផលវិបាកជាយថាហេតុនៃអំពើពុករលួយគ្រប់រូបភាពដែលកើតឡើងចំពោះដំណើរការនីតិវិធី ដូចដែលបានចោទប្រកាន់ដោយ ក.ស.ច.ស នោះទេ។ សន្មតថា អ្វីដែលបានរាយការណ៍ដោយ The Economist គឺជាការពិត នោះនឹងមានការប៉ះពាល់ដ៏ពិតប្រាកដពីអំពើពុករលួយ ក្នុងចំណោមបុគ្គលិកមួយចំនួននៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលនឹងប៉ះពាល់ដោយផ្ទាល់ទៅលើការធ្វើសេចក្តីសម្រេចពិតប្រាកដរបស់ ក.ស.ច.ស ក្នុងដំណាក់កាលស៊ើបសួរ។

### ខ. ភស្តុតាងនៃអំពើពុករលួយនៅ អ.វ.ត.ក អាចប៉ះពាល់ដល់ដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌

៤១. ក្តីកង្វល់ទាក់ទងនឹងផលប៉ះពាល់ទៅលើដំណើរការនីតិវិធី ប្រកបដោយយុត្តិធម៌ដែលបង្កឡើងដោយការចោទប្រកាន់នៃអំពើពុករលួយ ត្រូវបានលើកឡើងយ៉ាងលំអិតនៅក្នុងសំណើមួយដែលរំលឹកថា ជនត្រូវចោទ/មេធាវីការពារក្តីពុំមានព័ត៌មានជាក់លាក់ ដូចជារបាយការណ៍ OIOS ដែលត្រូវបានពួកគេយោងនោះឡើយ។ ប្រសិនបើរបាយការណ៍ OIOS មិនត្រូវបានគេផ្តល់ឱ្យនោះទេ តាមលក្ខណៈធម្មជាតិរបស់វា ការចោទប្រកាន់ គឺគ្រាន់តែជាការស្មានៗតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ខណៈដែលអំពើពុករលួយដែលអាចប្រព្រឹត្តឡើងដោយបុគ្គលិកការិយាល័យរដ្ឋបាលជាការពិត វាគឺជាការប្រមើលមើល ហើយតួនាទី និង ការទទួលខុសត្រូវពិតប្រាកដរបស់ពួកគេដែលបានកំណត់នៅក្នុងសំណើ គឺផ្អែកលើតួនាទីរបស់ពួកគេ ដូចបានកំណត់នៅក្នុងវិធានផ្ទៃក្នុង[78]។ តួនាទីទាំងនេះ ត្រូវបានគាំទ្រដោយលក្ខខណ្ឌការងារសំរាប់មុខដំណែងនៅក្នុង ក.ស.ច.ស ដូច

[78] សំណើ កថាខណ្ឌ ១៥ ។

ដែលបានផ្សព្វផ្សាយនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក[79]។ ការណ៍ដែល ក.ស.ច.ស ច្រានចោលដីកា ដោយផ្អែកលើមូលហេតុដែលថា ការចោទប្រកាន់ គឺជាការប្រមើលមើល អាស្រ័យហេតុនេះ វាបានដាក់បន្ទុកកាន់តែខ្លាំងមកលើជនត្រូវចោទ/មេធាវីការពារក្តី។

៤២. បន្ថែមពីលើនេះ <u>សំណើនេះមិនសំអាងតែទៅលើករណីអំពើពុករលួយដាច់ដោយឡែកតែមួយ ដើម្បីពន្យល់ពីផលប៉ះពាល់នៃជំងឺមហារីកនេះ ទៅលើដំណើរការនីតិវិធីតុលាការប្រកបដោយយុត្តិធម៌នោះទេ</u> សំណើនេះបានពិពណ៌នាយ៉ាងលំអិតអំពីការចោទប្រកាន់នៃអំពើពុករលួយយ៉ាងធំធេង ដែលបានផ្សព្វផ្សាយនៅក្នុងសារព័ត៌មានកម្ពុជា និង សារព័ត៌មានអន្តរជាតិ នៅក្នុងអំឡុងពេលជាងពីរឆ្នាំនៃដំណើរការនីតិវិធីរបស់តុលាការ[80]។ មានសេចក្តីរាយការណ៍ថា ការចោទប្រកាន់នៃអំពើពុករលួយទាំងនេះ ត្រូវបានពិភាក្សាដោយលោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក និង ប្រតិភូអាឡឺម៉ង់[81]។ <u>អនុលោមទៅតាមខ្លឹមសារនៃសេចក្តីរាយការណ៍ លោក Knut Rosandhaug បាន ពិពណ៌នាថា សេចក្តីសន្និដ្ឋាននៃការស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិបានបង្ហាញថា អង្គការសហប្រជាជាតិបានរកឃើញលោក ស៊ាន វិសុទ្ធ ប្រធានរដ្ឋបាលនៅ អ.វ.ត.ក មាន "ទោសពីអំពើ ពុករលួយ" ដូចបានបង្ហាញនៅក្នុងរបាយការណ៍ OIOS មែន</u>[82]។ ការចោទប្រកាន់ទាំងនេះក៏បានផ្សព្វផ្សាយបន្ថែមទៀតកាលពីពេលថ្មីនេះដោយទូរទស្សន៍ CNN និងទស្សនាវដ្តី The Economist ។ ចំពោះ ក.ស.ច.ស អះអាងថា សំណើគ្រាន់លើកឡើងនូវការប្រមើលមើល "ពីអំពើពុករលួយ" ហេតុដូច្នេះ វាអាចបញ្ជាក់ថា ក.ស.ច.ស ចាត់ទុកថា ទាំងលោក Knut Rosandhaug និង ប្រតិភូអាឡឺម៉ង់កំពុង និយាយកុហក ឬ យ៉ាងហោចណាស់ មានការភាន់ច្រឡំពីអំពើពុករលួយ។ ដើម្បីច្រានចោលការលើកឡើងរបស់អនុប្រធាន

---

[79] សូមមើលលក្ខខណ្ឌការងាររបស់ជំនួយការច្បាប់ P2 នៅការិយាល័យរដ្ឋបាល ឯកសារយោង EC-AN-07-1214, មន្ត្រីច្បាប់ P4 នៅការិយាល័យរដ្ឋបាល ឯកសារយោង EC-AN-08-1225, ជំនួយការបុគ្គលិកជាន់ខ្ពស់ P2 នៅការិយាល័យរដ្ឋបាល ឯកសារយោង EC-AN-07-0116 ។

[80] សំណើ កថាខណ្ឌ ៤ ដល់ ១១ ។

[81] ប្រតិភូសមាជិករដ្ឋសភា Bundestag "របាយការណ៍ [ព្រាង] ស្តីពីទស្សនៈកិច្ចនៅកម្ពុជា និង ឥណ្ឌូនេស៊ី ដោយប្រតិភូនៃគណៈកម្មាធិការសិទ្ធិមនុស្ស និង ជំនួយមនុស្សធម៌ ពីថ្ងៃទី២៥ ខែ តុលា ដល់ ថ្ងៃទី៣ ខែ វិច្ឆិកា ២០០៨ "របាយការណ៍ប្រតិភូអាឡឺម៉ង់")។

[82] *Id* ។

ការិយាល័យថាជាការប្រមើលមើល នៅពេលគាត់ពិតជាបានពិនិត្យឡើងវិញនូវរបាយការណ៍របស់ OIOS គឺពិតជាការបន្លំបោកប្រាស់ទាំងស្រុង[83]។

៤៣. តាមពិត ក.ស.ច.ស គ្រាន់តែចង់ដាក់មកលើមេធាវីការពារដោយចេតនានូវ Catch-22 situation ប៉ុណ្ណោះ[84]។ ក.ស.ច.ស នឹងមិនអនុញ្ញាតលើសំណើសុំព័ត៌មាននោះទេ ពីព្រោះការប៉ះពាល់នៃអំពើពុករលួយ មិនត្រូវបានពិពណ៌នាឱ្យបានច្បាស់លាស់។ វាមិនអាចជំទាស់បានទេ ប្រសិនបើព័ត៌មានដែលបានស្នើសុំមិនអាចទទួលបាន នោះភាពជាក់លាក់ច្រើនថែមទៀតទាក់ទងនឹងការចោទប្រកាន់ទាំងនេះ និង ផលប៉ះពាល់របស់វាទៅលើដំណើរការនីតិវិធី គឺពិតជាមិនអាចធ្វើបានទេ។ មធ្យោបាយតែមួយគត់ដើម្បីជំនះនូវភាពទាល់ច្រកនេះ គឺត្រូវផ្តល់ព័ត៌មានដែលបានស្នើសុំនេះដល់មេធាវីការពារក្តី។ ដូច្នេះទើបមានបណ្តឹងឧទ្ធរណ៍នេះឡើង។

## ឃ. របាយការណ៍ OIOS មិនមែនជាកម្មសិទ្ធិរបស់រដ្ឋាភិបាលកម្ពុជានោះទេ ប៉ុន្តែវាជាកម្មសិទ្ធិរបស់អង្គការសហប្រជាជាតិ ហើយវាជាកម្មវត្ថុនៃការលាតត្រដាង

៤៤. គេមិនអាចបំភ្លើសថា របាយការណ៍ OIOS មិនត្រូវបានអនុញ្ញាតិដោយរាជរដ្ឋាភិបាលកម្ពុជា ប៉ុន្តែរបាយការណ៍នេះត្រូវបានផ្តួចផ្តើមឡើងដោយភាគីអង្គការសហប្រជាជាតិនៃ អ.វ.ត.ក។ បើទោះបីជា របាយការណ៍នេះត្រូវបានផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជាក៏ដោយ ក៏អង្គការសហប្រជាជាតិនៅតែជាម្ចាស់កម្មសិទ្ធិលើវាដដែល។ អាស្រ័យហេតុនេះ អង្គការសហប្រជាជាតិមិនត្រូវបិទបាំងពី

---

[83] បើតាមការយល់ឃើញរបស់មេធាវីការពារ វាមានសារៈសំខាន់ណាស់ដើម្បីកត់សំគាល់ថា ទាំងប្រតិភូអាឡឺម៉ង់ និង លោក Knut Rosandhaug បានបដិសេធអំពើការចោទប្រកាន់នៃអំពើពុករលួយ ដូចដែលបានលើកឡើងដោយរបាយការណ៍របស់ប្រតិភូអាឡឺមង់

[84] ពាក្យស្លោកនេះយកស្រង់ចេញពីសៀវភៅប្រលោមលោកឆ្នាំ ១៩៦១ ដោយអ្នកនិពន្ធ Josef Heller ទាក់ទងនឹងដំណាក់កាលចុងក្រោយនៃសង្គ្រាមលោកលើកទី២ ។ សៀវភៅនេះពិពណ៌នាពីវិបាក បទបញ្ញាផ្ទៃក្នុង ឬ នីតិវិធី ឬ ស្ថានភាពដែលបង្ហាញពីការជ្រើសរើសដោយភាន់ច្រឡំ នៅពេលដែលកំពុងទប់ស្កាត់ការជ្រើសរើសត្រឹមត្រូវមួយ។ គំរូដើមនៃ Chatch22 ដែលបង្កើតឡើងដោយ Heller ពាក់ព័ន្ធជាមួយករណី John Yossrian អ្នកបើកបរយន្តហោះទម្លាក់គ្រាប់បែកនៃកងទ័ពអាកាសអាមេរិកដែលមានបំណងលាឈប់ពីភារកិច្ចហោះហើរប្រយុទ្ធ។ ការចង់លាឈប់ពីភារកិច្ចហោះហើរប្រយុទ្ធ គាត់ត្រូវតែបានវាយតំលៃជាផ្លូវការដោយគ្រូពេទ្យវះកាត់របស់កងហោះហើរប្រយុទ្ធ ហើយត្រូវតែរកឃើញថា គាត់គ្មានសម្បទានដើម្បីហោះហើរ ដែលនឹងក្លាយជារោគវិនិច្ឆ័យស្វាយជាស្វាយប្រវត្តិរភាពលីលារបស់អ្នកបើកបរយន្តហោះ ដោយសារមានតែមនុស្សឆ្កួតទេ អាចប្រឡូកក្នុងបេសកម្មពីព្រោះតែភាពគ្រោះថ្នាក់ ។ ប៉ុន្តែ ដើម្បីទទួលបានរោគវិនិច្ឆ័យ គាត់ត្រូវតែស្នើសុំ ហើយ ដើម្បីទទួលបានរោគមួយ គាត់ត្រូវបង្ហាញពីភាពលីលាគ្រប់គ្រាន់ ដើម្បីឱ្យគេបញ្ឈប់គាត់ពីការហោះហើរ។

ក្រោយការបដិសេធរបស់រដ្ឋាភិបាលកម្ពុជាលើសំណើសុំរបាយការណ៍របស់មេធាវីការពារបានទេ ហើយនៅក្នុងករណីនេះ មេធាវីការពារបានស្នើសុំរួចមកហើយកាលពីអតីតកាល[85]។

៤៥. អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងការបង្កើត និង ដំណើរការរបស់ អ.វ.ត.ក ដោយសារតែគោលបំណងដែលខ្លួនចង់បាន គឺដើម្បីធានាថាការជំនុំជម្រះក្តីលើពួកខ្មែរក្រហមត្រូវប្រព្រឹត្តទៅដោយយុត្តិធម៌ ដោយគោរពយ៉ាងពេញលេញដល់ដំណើរការត្រឹមត្រូវតាមច្បាប់[86]។ អង្គការសហប្រជាជាតិបានសម្តែងការព្រួយបារម្ភរបស់ខ្លួនជាថ្មីម្តងទៀតថា មានអំពើពុករលួយជាដុំកំភួននៅក្នុងប្រព័ន្ធតុលាការកម្ពុជា[87]។ ដំបូងឡើយ អង្គការសហប្រជាជាតិស្នើឲ្យបង្កើតតុលាការអន្តរជាតិពេញលេញមួយ ដែលជាមធ្យោបាយតែមួយគត់ ដើម្បីធានានូវការជំនុំជម្រះក្តីដោយយុត្តិធម៌ និងការពារប្រឆាំងនឹងការចូលជ្រៀតជ្រែកខាងនយោបាយ និងអំពើពុករលួយ[88] ហើយថែមទាំងបានដកខ្លួនចេញពីកិច្ចចរចារ នៅពេលខ្លួនយល់ថា ភាពយុត្តិធម៌នេះមិនត្រូវបានធានា

---

[85] សូមមើលសំណើ កថាខណ្ឌ ១២។ សូមមើលផងដែរ សេចក្តីប្រកាសព័ត៌មានឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់លោក Peter Taksoe-Jensen ឧបការីអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកកិច្ចការច្បាប់ ចុះថ្ងៃទី ៨ មេសា ២០០៩ ដោយលោក អាង ឧត្តម និង Michael G. Karnavas សហមេធាវីរបស់លោក អៀង សារី ចុះថ្ងៃទី៩ មេសា ២០០៩ ដែលសហមេធាវីទាំងពីរ “បានស្នើសុំដោយក្តីគោរពដល់លោក Peter Taksoe-Jensen ឱ្យផ្តល់របាយការណ៍ OIOS មកក្រុមមេធាវីការពារទាំងអស់នៅ អ.វ.ត.ក ជាបន្ទាន់” ។

[86] សូមមើល ឧទាហរណ៍ ប្រតិចារិតនៃការពន្យល់របស់លោក Hans Correl អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិទទួលកិច្ចការច្បាប់ និង មេធាវីរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ៨ កុម្ភះ ២០០២ ហើយត្រូវបានផលិតឡើងវិញនៅក្នុងសៀវភៅរបស់ Helen Jarvis “សវនាការ និង តុលាការ: របត់ចុងក្រោយក្នុងការស្វែងរកយុត្តិធម៌យ៉ាងយូរសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, Critical Asian Study 34:4(2002) 607, 617 (“ប្រតិចារិតចុះថ្ងៃទី៨ កុម្ភះ ២០០២”)។ នៅក្នុងសេក្តីពន្យល់នេះ លោក Hans Correl បានលើកឡើងថា “បទដ្ឋានយុត្តិធម៌អន្តរជាតិ គឺចាំបាច់សម្រាប់ការបន្តការចូលរួមរបស់អង្គការសហប្រជាជាតិ” ។

[87] “កម្រិតអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ និង ទម្លាប់ដាក់សេចក្តីសម្រេចរបស់តុលាការនៅក្រោមឥទ្ធិពលនយោបាយធ្វើឲ្យព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និង ចៅក្រម ពិបាករួចផុតពីការគាបសង្កត់បែបនេះណាស់ នៅខណៈជំនុំជម្រះក្តីនូវអ្វីដែលជាការចោទប្រកាន់ខាងនយោបាយ។ សេចក្តីសម្រេចលើការស៊ើបអង្កេត ចោទប្រកាន់ និង ផ្តន្ទាទោស ឬ លើកលែងចោទប្រកាន់នរណាម្នាក់ ត្រូវពឹងផ្អែកលើភស្តុតាង និងមិនត្រូវបំរើរបៀបវារៈនយោបាយនៃគណបក្សនយោបាយ ឬ ក្រុមនយោបាយណាមួយឡើយ។ វាជាការចាំបាច់សម្រាប់គោរពសុច្ចភាពនៃដំណើរការនីតិវិធី និង គោរពសិទ្ធិជាមូលដ្ឋានរបស់ចុងចោទ”។ របាយការណ៍របស់ក្រុមជំនាញការសម្រាប់កម្ពុជា ដែលបង្កើតឡើងស្របតាមដំណោះស្រាយរបស់អង្គការសហប្រជាជាតិ លេខ 52/135, 22.2.1999 កថាខណ្ឌ ១៣៣ (បញ្ជាក់បន្ថែម)។

[88] *Id* កថាខណ្ឌ ១៣៩។

ដោយប្រព័ន្ធតុលាការ ដែលស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា[89]។ ដោយថាហេតុ ប្រព័ន្ធតុលាការដែលបានស្នើឡើងដោយកិច្ចចរចារ ធានាឲ្យមាន ការចូលរួមយ៉ាងទូលំទូលាយពីអន្តរជាតិនៅគ្រប់កម្រិតទាំងអស់នៃ អ.វ.ត.ក។ តាមពិត សហចៅក្រមស៊ើបអង្កេតម្នាក់នៃសហចៅក្រមស៊ើបអង្កេតទាំងពីរ គឺជាចៅក្រមអន្តរជាតិ ហើយការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវមានទាំងបុគ្គលិកជាតិ និង បុគ្គលិកអន្តរជាតិ ។

៤៦. ឥឡូវនេះ បញ្ហាអំពើពុករលួយកំពុងត្រូវបានដោះស្រាយក្នុងរបៀបលាក់ពុត ដោយអង្គការសហប្រជាជាតិ ថាជាបញ្ហានយោបាយ។ ស្របពេលជាមួយគ្នានេះ អង្គការសហប្រជាជាតិពិតកំពុងតែប៉ុនប៉ងយ៉ាងឆ្លាតវៃដើម្បីឲ្យបញ្ហានេះរលត់បាត់ទៅវិញ ដោយពុំមានផលវិបាកផ្នែកច្បាប់បន្ថែមទៀត តាមរយៈការធ្វើឲ្យបញ្ហានេះកាន់តែស្មុគស្មាញថែមទៀត។ ជាជាងអំពាវនាវឲ្យមានការស៊ើបអង្កេតពេញលេញ និង តម្លាភាពទៅលើការប៉ះពាល់នៃអំពើពុករលួយ ទៅលើការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលមួយផ្នែកស្ថិតនៅក្រោមទង់របស់អង្គការសហប្រជាជាតិ អង្គការសហប្រជាជាតិបាននិយាយជាសាធារណៈអំពីតម្រូវការ "ទុកអំពើពុករលួយមួយកន្លើ"[90]។ ដោយប្រើរាជរដ្ឋាភិបាលកម្ពុជា ជា "ខែល" ដើម្បីទប់ស្កាត់ទាំងស្រុងនូវការបង្ហាញរបាយការណ៍ ដែលការនេះគឺពិតជាផ្ទុយនឹងផលប្រយោជន៍ខាងយុត្តិធម៌។ អង្គការសហប្រជាជាតិ ដែលតស៊ូមតិឲ្យមានសុច្ចរិតភាព និង តម្លាភាពនៅតុលាការនៅទូទាំងពិភពលោក បែរជាប្រព្រឹត្តការឆ្កាំឆ្កងដោយលាក់ខ្លួននៅខាងក្រោយខ្នងរាជរដ្ឋាភិបាលកម្ពុជាទៅវិញ ហើយស្របពេលជាមួយគ្នានេះ បានកំពុងអះអាងខ្លួនថាមានឆន្ទះប្រៀនប្រដៅប្រឆាំងនឹងការប្រព្រឹត្តិអំពើពុករលួយ។

## ខ. ជាជម្រើស ប្រសិនបើ ក.ស.ច.ស អាចទទួលរបាយការណ៍របស់ OIOS តែឯងពីរដ្ឋាភិបាលកម្ពុជា នោះលក្ខណៈវិនិច្ឆ័យចាំបាច់ទាំងអស់សម្រាប់ផ្តល់មកជាមួយរបាយការណ៍នេះត្រូវបានឆ្លើយតប

[89] ការិយាល័យកិច្ចការច្បាប់នៃអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ បានប្រកាសកាលពីថ្ងៃទិ ៨ កុម្ភៈ ២០០២ ថា ខ្លួនបានបញ្ចប់កិច្ចចរចារជាមួយរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការបង្កើតសាលាក្តីខ្មែរក្រហម។ ក្នុងអំឡុងពេលសន្និសីទ្ធកាសែត លោក Hans Correl បានពន្យល់ថា ការដកខ្លួនរបស់អង្គការសហប្រជាជាតិ គឺដោយសារតែ "អង្គជំនុំជម្រះវិសាមញ្ញា នឹងមិនអាចធានាឯករាជ្យភាព និង អនាគតិ និង គោលបំណងដែលថា តុលាការមួយត្រូវបានបង្កើតឡើងដោយការគាំទ្រពីអង្គការសហប្រជាជាតិត្រូវមាន" ចុះថ្ងៃទី ៨ កុម្ភៈ ២០០២, ប្រតិចារិតលេខ ៦១៧ ។

[90] សេចក្តីថ្លែងការណ៍របស់លោក Taksoe Jensen, សូមមើលផងដែរអត្ថបទរបស់លោក សុខ ខេមរា ។

១. ការស្នើសុំជំនួយ

៤៧. ដូចដែលបានលើកឡើងខាងលើ តាមការយល់ដឹងយ៉ាងច្បាស់របស់មេធាវីការពារ របាយការណ៍របស់ ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង (OIOS) និងព័ត៌មានបន្ថែម គឺស្ថិតនៅក្នុងការកាន់កាប់ និងការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ។ ប៉ុន្តែ ប្រសិនបើវាមិនដូច្នោះទេ នោះ ក.ស.ច.ស ឬ អង្គបុរេជំនុំជម្រះអាចទទួលទទួលបានរបាយការណ៍របស់ OIOS ពីរដ្ឋាភិបាលកម្ពុជាបាន តែក្នុងករណីដែលមានការស្នើសុំជំនួយ ដោយអនុលោមតាមមាត្រា ២៥ នៃកិច្ចព្រមព្រៀងតែប៉ុណ្ណោះ។ បទប្បញ្ញត្តិនេះចែងថា "រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តដោយគ្មានការពន្យារពេល តាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គបុរេជំនុំជម្រះ ឬក៏បញ្ជារបស់ពួកគេ"[91]។ លក្ខខណ្ឌផ្នែកនីតិវិធីសម្រាប់ RFA នេះត្រូវបាន អនុវត្តតាម។

៤៨. វាត្រូវបានដោះស្រាយនៅក្នុងយុត្តិសាស្ត្រអន្តរជាតិថា ភាគីមួយដែលធ្វើការស្វែងរកការបង្ហាញឯកសារ ឬ ព័ត៌មានពីរដ្ឋមួយ ត្រូវតែ៖

ក. កំណត់អត្តសញ្ញាណឯកសារ ឬព័តមានដែលទាក់ទងទៅនឹងការស្នើតាមដែលអាចធ្វើទៅបាន

ខ. បញ្ជាក់ថាតើ វាពាក់ព័ន្ធទៅនឹងបញ្ហាណាមួយនៅក្នុងកម្មវត្ថុដោយរបៀបណា នៅចំពោះមុខអង្គជំនុំជម្រះ និងចាំបាច់ដោយរបៀបណាសម្រាប់ការសម្រេចទៅលើបញ្ហានោះ និង

គ. ពន្យល់ពីដំណាក់កាលដែលធ្វើឡើងដោយភាគីស្នើសុំ ដើម្បីធានាឲ្យមានការផ្តល់ជំនួយពីរដ្ឋនោះ។[92]

៤៩. មុននឹងមានការស្នើសុំឲ្យមានដំណោះស្រាយពីអង្គជំនុំជម្រះ ភាគីស្នើសុំមានកាតព្វកិច្ចបង្ហាញឲ្យឃើញថា ខ្លួនបានខិតខំប្រឹងប្រែងប្រកបដោយហេតុផល បញ្ចុះបញ្ចូលឲ្យរដ្ឋនោះផ្តល់ព័ត៌មានដែល

---

[91] គួសបញ្ជាក់បន្ថែម។

[92] វិធាន ៥៤ស្ទួន(ក), វិធាននៃនីតិវិធី និងភស្តុតាងរបស់ ICTY ។ សូមមើលផងដែរ រដ្ឋអាជ្ញា តទល់នឹង Milutinovic និង អ្នកផ្សេងទៀត, IT-05-87-T, សេចក្តីសម្រេចទៅលើការស្នើសុំឲ្យធ្វើវិសោធនកម្មវិធាន ៥៤ស្ទួន របស់ Sreten Likic ចុះថ្ងៃទី ២៩ កញ្ញា ២០០៦ កថាខណ្ឌ ៦ ។

បានស្នើសុំដោយស្ម័គ្រចិត្ត។[93] វៀរលែងតែរដ្ឋនោះបដិសេធមិនផ្ដល់ការគាំទ្រដែលបានស្នើសុំ នោះទើបភាគីស្នើសុំ អង្គជំនុំជម្រះឱ្យចាត់វិធានការតាមផ្លូវច្បាប់។[94]

៥០. ទីមួយ ឯកសារ ឬព័ត៌មានជាក់លាក់ដែលទាក់ទងទៅនឹងការស្នើសុំ ត្រូវបានកំណត់អត្តសញ្ញាណ។[95] ទីពីរ សំណើសុំនេះ និង ពិតណាស់ហើយ បណ្ដឹងឧទ្ធរណ៍នេះលើកឡើងជាលំអិត ថាតើរបាយការណ៍នេះ ព្រមទាំងព័ត៌មាន ដែលបានស្នើសុំទាំងអស់គឺជាបច្ច័យសំខាន់ចំពោះបញ្ហាថាតើ ជនត្រូវចោទកំពុងត្រូវបានស៊ើបសួរប្រកបដោយយុត្តិធម៌ និងដោយឥតលំអៀងដែរឬយ៉ាងណា។[96] ទីបី សំណើសុំនេះនេះក៏បានលើកឡើងលំអិតពីដំណាក់កាល ដែលបានធ្វើឡើងដោយមេធាវីការពាររបស់ នួន ជា ដើម្បីធានាឱ្យទទួលបានរបាយការណ៍របស់ OIOS និងព័ត៌មានពាក់ព័ន្ធពីអាជ្ញាធររាជរដ្ឋាភិបាលកម្ពុជាដោយផ្ទាល់។[97]

## ២. ការស្នើសុំឱ្យធ្វើការបង្ហាញ

៥១. ជាជម្រើស ចំពោះវិសាលភាពដែលថា អង្គបុរេជំនុំជម្រះពិចារណាថា សំណើនេះឆ្លុះបញ្ចាំងពីសំណើ សុំឱ្យធ្វើការបង្ហាញមួយនៅ ICTY និង ICTR នោះលក្ខខណ្ឌផ្នែកនីតិវិធីសំខាន់ៗសម្រាប់សំណោះសុំប្រភេទនេះត្រូវបានបំពេញ។

៥២. សំណើសុំឱ្យធ្វើការបង្ហាញត្រូវតែ: (១) អះអាងថា ឯកសារដែលបានស្នើសុំនេះ គឺស្ថិតនៅក្នុងការកាន់កាប់របស់សហព្រះរាជអាជ្ញា (ឬក្នុងករណីនេះ គឺ ក.ស.ច.ស) និង (២) ត្រូវតែបង្ហាញពីករណីសច្ចធារណ៍ (*prima facie* case) ថា ឯកសារដែលបានស្នើសុំនេះ គឺជាភស្តុតាងដោះបន្ទុក។[98]

---

[93] រដ្ឋអាជ្ញា តទល់នឹង Milutinovic និង អ្នកផ្សេងទៀត, IT-05-87-T, សេចក្ដីសម្រេចស្ដីពីសំណើសុំលើកទីពីររបស់ Dragoljub Ojdanic ចំពោះដីកាសម្រេចចងកាតព្វកិច្ច ដោយអនុលោមតាមវិធាន ៥៤ស្ទួន ចុះថ្ងៃទី១៧ វិច្ឆិកា ២០០៥ កថាខណ្ឌ ៧ ។

[94] រដ្ឋអាជ្ញា តទល់នឹង Milutinovic និងអ្នកផ្សេងទៀត, IT-05-87-AR108bis.2, សេចក្ដីសម្រេចស្ដីពីសំណើសុំរបស់សហរដ្ឋអាមេរិកសុំឱ្យធ្វើការពិនិត្យឡើងវិញ ចុះថ្ងៃទី១២ ឧសភា ២០០៦ កថាខណ្ឌ ៣២ ។

[95] សំណើសុំ, កថាខណ្ឌ ២២, ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ៤, សូមមើល កថាខណ្ឌ ៣៧-៣៨ ខាងក្រោម។

[96] សំណើសុំ, កថាខណ្ឌ ១៨-២១, សូមមើលផងដែរ កថាខណ្ឌ ៤១-៤៣ ខាងក្រោម។

[97] ដូចគ្នា, កថាខណ្ឌ ១២ ។

[98] រដ្ឋអាជ្ញា តទល់នឹង Kajelijeli, សាលដីកា, ICTR-98-44-A, ចុះថ្ងៃទី ២៣ ឧសភា ២០០៥ កថាខណ្ឌ ២៦២, រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez, IT-95-14/2-A, សាលដីកា, ចុះថ្ងៃទី ១៧ ធ្នូ ២០០៤ កថាខណ្ឌ ១៧៨, រដ្ឋអាជ្ញា តទល់នឹង Brđanin, IT-99-36-A, សេចក្ដីសម្រេចស្ដីពីសារណារបស់ដើមបណ្ដឹងឧទ្ធរណ៍សុំឱ្យធ្វើការបង្ហាញ ដោយអនុលោម

៩៣. តាមការយល់ដឹងយ៉ាងច្បាស់លាស់របស់មេធាវីការពារ របាយការណ៍ OIOS និងព័ត៌មានដែលបានស្នើសុំផ្សេងទៀត សព្វថ្ងៃនេះមិនស្ថិតនៅក្នុងការកាន់កាប់ដោយ ក.ស.ច.ស ឡើយ។ ដីកាសម្រេចរបស់ ក.ស.ច.ស មិនបានផ្តល់ការបញ្ជាក់បន្ថែមណាផ្សេងទៀតទេ។ ប៉ុន្តែ អាចនិយាយថា ក.ស.ច.ស បានទទួលច្បាប់ចម្លងនៃរបាយការណ៍របស់ OIOS និងគ្រាន់តែបានសម្រេចមិនដាក់ច្បាប់ចម្លងនៃរបាយការណ៍នេះទៅក្នុងសំណុំរឿងតែប៉ុណ្ណោះ ដោយសារថា របាយការណ៍នេះ "មិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរ "។[99] ហេតុដូច្នេះ របាយការណ៍នេះអាចស្ថិតនៅក្នុងការកាន់កាប់របស់ ក.ស.ច.ស ហើយផ្នែកទីមួយនៃតេស្តសម្រាប់ការស្នើសុំឲ្យធ្វើការបង្ហាញនេះ ត្រូវបានបំពេញ។

៩៤. សម្រាប់ផ្នែកទីពីរនៃតេស្តនេះ លក្ខណៈនៃព័ត៌មានដោះបន្ទុក ឬប្រសិទ្ធភាពស្តីពីភាពត្រឹមត្រូវនៃដំណើរការនីតិវិធីនៃព័ត៌មានដែលបានស្នើសុំ ត្រូវបានលើកឡើងយ៉ាងទូលំទូលាយដូចមាននៅខាងលើ[100] និងនៅក្នុងសំណើសុំនេះ។[101]

## VI. សេចក្តីសន្និដ្ឋាន និង ការស្វែងរកដំណោះស្រាយ

៩៥. លោក Marcel Lemonde ដែលជាចៅក្រមអន្តរជាតិ បានមានប្រសាសន៍កាលពីពេលកន្លងមកថា៖

"ចៅក្រមអន្តរជាតិបានអះអាងថា ពួកគាត់មិនអាចចូលរួមនៅក្នុងដំណើរការកាត់សេចក្តីមួយដែលមិនមែនជាការកាត់សេចក្តីប្រកបដោយយុត្តិធម៌ នៅចំពោះមុខសាលាជម្រះក្តីមួយដែលឯករាជ្យ និងអនាគតិបានទេ [...]។ 'នេះជាបញ្ហាមួយដែលមិនអាចចរចារបានទេ ហើយប្រសិនបើមិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌ

តាម វិធាន ៦៨ និង សារណាស្នើសុំឲ្យមានដីកាសម្រេចឲ្យក្រឡាបញ្ជីបង្ហាញឯកសារមួយចំនួន, ចុះថ្ងៃទី ៧ ធ្នូ ២០០៤, ទំព័រ ៣។ រដ្ឋអាជ្ញា តទល់នឹង Blaškić, . IT-95-14-A, សាលដីកា ចុះថ្ងៃទី ២៩ កក្កដា ២០០៤ កថាខណ្ឌ ២៦៨។ រដ្ឋអាជ្ញា តទល់នឹង *Sesay* និង អ្នកផ្សេងទៀត SCSL-04-15-T, សេចក្តីសម្រេចទៅលើសំណើសុំផ្ទាល់មាត់ចំពោះការច្រានចោលកំណត់ហេតុផ្តល់ចម្លើយ "បន្ថែមទៀត" សម្រាប់សាក្សី TF1-060, ចុះថ្ងៃទី ២៣ កក្កដា ២០០៤ កថាខណ្ឌ ៩។ រដ្ឋអាជ្ញា តទល់នឹង *Norman* និង អ្នកផ្សេងទៀត, SCSL-04-14-PT, សេចក្តីសម្រេចស្តីពីការបង្ហាញកំណត់ហេតុផ្តល់ចម្លើយសាក្សី និងការសួរតទល់គ្នា, ចុះថ្ងៃទី ១៦ កក្កដា ២០០៤, កថាខណ្ឌ ៧។

[99] ដីកាសម្រេចរបស់ ក.ស.ច.ស, កថាខណ្ឌ ១០ ។

[100] សូមមើលកថាខណ្ឌ ៣៩-៤៣ ខាងក្រោម ។

[101] សំណើសុំ, កថាខណ្ឌ ១៨-២១ ។

ទាំងនេះទេ នោះចៅក្រមទាំងឡាយមិនមានជម្រើសអ្វីក្រៅតែពីការស្នើសុំឱ្យ អ.ស.ប ដកខ្លួនចេញនោះទេ' [...]។ "នេះមិនមែនជាការគំរាមកំហែង ឬកាន់តែអាក្រក់ជាងនេះទៅទៀត វាមិនមែនជាការកម្លានោះទេ តែវាជាតថភាពពិត"[102]។

៥៦. ទោះជាយ៉ាងណាក៏ដោយ ចៅក្រម Lemonde នាពេលថ្មីៗនេះបានទទួលស្គាល់ថា "មានបរិយាកាសពុករលួយ" នៅ អ.វ.ត.ក។[103] នៅពេលដែលមេធាវីការពារបានដាក់ជូននូវឱកាសសមហេតុសមផល ដើម្បីបញ្ជាក់ឱ្យច្បាស់ថាតើ ការចោទប្រកាន់ពីអំពើពុករលួយដែលធ្ងន់ធ្ងរ និងមាននិរន្តរភាព នៅ អ.វ.ត.ក អាចនាំឱ្យមានការជំនុំជម្រះក្តីមួយដែលអយុត្តិធម៌ ដែលតម្រូវឱ្យចៅក្រមបរទេសដកខ្លួន ឬយ៉ាងណានោះ ក.ស.ច.ស បានជ្រើសរើសយកការមិនអើពើ (bury its head in the sand) និងបដិសេធសំណើសុំនេះចោលទៅវិញ។ ការបដិសេធនេះក៏ត្រូវបានសម្រេចឡើងដោយការពិចារណាមិនបានត្រឹមត្រូវប្រញាប់ប្រញាល់ពេក បើប្រៀបធៀបទៅនឹងសំណើផ្សេងៗទៀតរបស់ជនត្រូវចោទ/មេធាវីការពារ ដែលត្រូវបានគេមិនអើពើ ឬទុកចោលនោះ។ ដីកាសម្រេចរបស់ ក.ស.ច.ស ត្រូវបានសំអាងបែបសន្មតទៅលើ "នីតិរដ្ឋ"[104] ដែលតាមពិតទៅ ការច្រានចោលសំណើសុំនេះ បង្កើតបានជាការរំលោភគោលការណ៍ដែលគួរឱ្យគោរពទៅវិញនោះ។ ជាការដែលមិនអាចជៀសរួចបាន បញ្ហានេះបង្កឱ្យមានចំណាប់អារម្មណ៍ថា ក.ស.ច.ស កំពុងតែគេចវៀសពីកាតព្វកិច្ចដែលមានមកជាមួយ និងមិនអាចកាត់ផ្តាច់បានដើម្បីធានាថា ដំណើរការនីតិវិធី គឺមានភាពត្រឹមត្រូវ។ បន្ទាប់ពីការខកខានម្តងហើយម្តងទៀត និងគួរឱ្យអស់សង្ឃឹម របស់ជំនួយការលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ ឯកឧត្តម H.E. Peter Taksoe-Jensen ក្នុងការផ្តល់របាយការណ៍មកឱ្យក្រុមមេធាវីការពារទាំងអស់នៅ អ.វ.ត.ក រួចមក មានតែអង្គបុរេជំនុំជម្រះទេដែលអាចធានាថា អ.ស.ប មិនចូលរួមសមគំនិតក្នុងអំពើពុករលួយ ក្នុងនាមជាអ្នកជួយ និងសម្រួល ក្រោយអង្គហេតុ តែផ្ទុយទៅវិញ ត្រូវតែជាកម្លាំងមួយសម្រាប់ជាប្រយោជន៍ក្នុងការកម្ចាត់ចោលអំពើពុករលួយនេះ។

---

102 Cat Barton, សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ២៣ កុម្ភៈ និង ៨ មីនា ២០០៧ [ការអះអាងថាមានអំពើពុករលួយប្រឡាក់ប្រឡូកនៅក្នុងសាលាក្តីខ្មែរក្រហម 'Kickback Claims Stain the KRT'] ។

103 ទស្សនាវដ្តី Economist ទំព័រ ៤ ។

104 ដីកាសម្រេចរបស់ ក.ស.ច.ស កថាខណ្ឌ ១១ ។

**អាស្រ័យហេតុនេះ** សម្រាប់ហេតុផលដូចដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ មេធាវីការពារ សូមស្នើដោយគោរពឲ្យ អង្គបុរេជំនុំជម្រះ÷

ក. **អនុញ្ញាត**ផ្តល់តាមសំណើសុំក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីលោក អៀង សារី

ខ. **បង្គាប់**ឲ្យ ក.ស.ច.ស ទទួលយក និងបង្ហាញជូនក្រុមមេធាវីការពារក្តីនៅ អ.វ.ត.ក ទាំងអស់ ទៅតាមពេលវេលាសមស្របរបស់ខ្លួននូវ:

i) លទ្ធផលនៃកច្ចសើុបសួររបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង (OIOS)

ii) រាល់លិខិតឆ្លើយឆ្លងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងកិច្ចសើុបសួររបស់ការិយាល័យសេវាកម្មត្រួតពិនិត្យផ្ទៃក្នុង (OIOS) និង

iii) ព័ត៌មានផ្សេងទៀតទាក់ទងទៅនឹងបទល្មើសពុករលួយជាស្ថាប័នដែលមានការរៀបចំទុកជាមុននៅ អ.វ.ត.ក។ រាល់ព័ត៌មានទាំងឡាយដែលលើកឡើងពីអំពើពុករលួយជាស្ថាប័នដែលមានប្រព័ន្ធរៀបចំចាត់ចែងជាមុននៅ អ.វ.ត.ក ។

គ. **កំណត់កាលបរិច្ឆេទ**សវនាការដេញដោលផ្ទាល់មាត់មួយ ទៅលើបណ្តឹងឧទ្ធរណ៍នេះនៅសប្តាហ៍នៃថ្ងៃទី ១ ដល់ទី ៥ នៃខែ មិថុនា ឆ្នាំ ២០០៩ ។

សូមចៅក្រមអង្គបុរេជំនុំជម្រះមេត្តាទទួលបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **០៤** ខែ**ឧសភា** ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**